# សៀវភៅណែនាំបច្ចេកទេសសម្រាប់កសិករ

# ការចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារ




| | |
|---|---|
| រៀបចំដោយ៖ | គម្រោងបញ្ជ្រាបយេនឌ័រ ដំណាក់កាលទី២ (PGM2/MOWA/JICA) |
| | មន្ទីរកសិកម្ម និងមន្ទីរកិច្ចការនារី ខេត្តកំពង់ចាម |
| ឧបត្ថម្ភដោយ៖ | ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) |
| សហការអនុវត្ត៖ | មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ចាម |
| | មន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តកំពង់ចាម |
| | មន្ទីរពាណិជ្ជកម្ម ខេត្តកំពង់ចាម |
| | មន្ទីរផែនការ ខេត្តកំពង់ចាម |



ខែ ឧសភា ២០១៤

# អារម្ភកថា

សៀវភៅណែនាំបច្ចេកទេសចិញ្ចឹមមាន់ សម្រាប់កសិករនេះ ត្រូវបានរៀបចំឡើងដោយគម្រោងបញ្ជ្រាបយេនឌ័រ ដំណាក់កាលទី២ (PGM2/MOWA/JICA) មន្ទីរកិច្ចការនារី និងមន្ទីរកសិកម្ម ខេត្តកំពង់ចាម ក្រោមកិច្ចសហការអនុវត្តដោយ មន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ មន្ទីរអភិវឌ្ឍន៍ជនបទ មន្ទីរពាណិជ្ជកម្ម និង មន្ទីរផែនការ ខេត្តកំពង់ចាម ដោយមានការជួយឧបត្ថម្ភគាំទ្រពីទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA)។ការចិញ្ចឹមមាន់ពូជក្នុងស្រុកជាលក្ខណៈគ្រួសារ មានសារៈសំខាន់ណាស់សម្រាប់ប្រជាកសិករ ជាពិសេសស្ត្រី ក្នុងការចូលរួមចំណែកលើកកំពស់ជីវភាពរស់នៅ តាមរយៈការបង្កើនអាហាររូបត្ថម្ភ និង ប្រាក់ចំណូលបន្ថែមសម្រាប់គ្រួសារ។ ប៉ុន្តែប្រជាកសិករមួយចំនួនធំ បាននិងកំពុងជួបប្រទះនូវបញ្ហាជាច្រើនក្នុងការចិញ្ចឹមមាន់ឲ្យបានជោគជ័យ ដោយសារការរាតត្បាតនៃជំងឺឆ្លងរាលដាលផ្សេងៗ និងការថែទាំមិនបានដិតដល់ ដែលទាំងនេះបណ្ដាលមកពីកង្វះខាតនូវចំណេះដឹងបច្ចេកទេសសមស្រប និង បទពិសោធន៍ល្អៗ ក្នុងការចិញ្ចឹមមាន់របស់ប្រជាកសិករ។

លើសពីនេះទៀត វាមានសារៈសំខាន់ណាស់ ក្នុងការគិតគូរធ្វើយ៉ាងណាផ្ដល់ឱកាសឲ្យស្ត្រីទទួលបានចំណេះដឹងបច្ចេកទេសចិញ្ចឹមមាន់សមស្រប។ ប្រជាកសិករ ជាពិសេសស្ត្រី អាចចូលរួមចំណែកលើកកំពស់សុខុមាលភាពគ្រួសារតាមរយៈសកម្មភាពចិញ្ចឹមមាន់នេះ។ ទោះជាយ៉ាងណាក្ដី កសិករជាស្ត្រីមានឱកាសតិចតួចធៀបនឹងកសិករជាបុរស ក្នុងការទទួលបានចំណេះដឹងបច្ចេកទេសចិញ្ចឹមមាន់។

ហេតុនេះហើយ សៀវភៅណែនាំបច្ចេកទេសចិញ្ចឹមមាន់នេះ ត្រូវបានចងក្រងឡើងសម្រាប់ប្រជាកសិករជាពិសេសស្ត្រី បានរៀនសូត្រនូវចំណេះដឹងបច្ចេកទេសចិញ្ចឹមមាន់មួយសមស្រប។ សៀវភៅណែនាំនេះ បរិយាយ និង ពន្យល់អំពីចំណេះដឹងបច្ចេកទេសចិញ្ចឹមមាន់ ដោយប្រើប្រាស់នូវរូបភាពងាយៗជាច្រើន ដែលធ្វើឲ្យប្រជាកសិករងាយស្រួលយល់។

យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា សៀវភៅណែនាំបច្ចេកទេសនេះ នឹងត្រូវបានប្រើប្រាស់ឆ្លើយតបនឹងតម្រូវការចាំបាច់របស់ប្រជាកសិករ ក្នុងការអនុវត្តន៍បច្ចេកទេសចិញ្ចឹមមាន់ឲ្យបានទទួលជោគជ័យ។

ជ. រដ្ឋមន្ត្រី
រដ្ឋលេខាធិការ

ច័ន្ទ សុរីយ៍

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាខេត្តកំពង់ចាម**
លេខៈ ...១៣៧...៤៥...កច

កំពង់ចាម ថ្ងៃទី ០៤... ខែ ឧសភា.. ឆ្នាំ ២០១៤

# លិខិតថ្លែងអំណរគុណ

សៀវភៅណែនាំបច្ចេកទេសចិញ្ចឹមមាន់ សម្រាប់កសិករនេះ ត្រូវបានបោះពុម្ពឡើងដោយផ្អែកលើបទពិសោធន៍នៃគម្រោងសាកល្បងផ្នែកផលិតកម្មកសិកម្ម ក្នុងខេត្តកំពង់ចាម ក្រោមគម្រោងបញ្ជ្រាបយេនឌ័រ ដំណាក់កាលទី២ (PGM2) ដែលបានអនុវត្តដោយក្រសួងកិច្ចការនារី (MOWA) ដោយមានការជួយឧបត្ថម្ភគាំទ្រពីទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA)។

ក្នុងនាមថ្នាក់ដឹកនាំខេត្តកំពង់ចាម ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ជូនចំពោះ លោកជំទាវវេជ្ជបណ្ឌិត **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ដែលបានផ្តល់ឱកាសឲ្យមន្ត្រីនៃមន្ទីរពាក់ព័ន្ធ ក្នុងខេត្តកំពង់ចាម ធ្វើការរួមគ្នាជាមួយមន្ត្រីក្រសួងកិច្ចការីនារី និង សមាជិកក្រុមការងារគម្រោងបញ្ជ្រាបយេនឌ័រ ដំណាក់កាលទី២ ក្នុងការអនុវត្តសកម្មភាពរបស់គម្រោងសាកល្បង និង ការចងក្រងសៀវភៅណែនាំបច្ចេកទេសនេះឡើង។

ទន្ទឹមនឹងនេះ ខ្ញុំសូមថ្លែងអំណរគុណ ចំពោះ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) ដែលបានជួយឧបត្ថម្ភគាំទ្រទាំងផ្នែកបច្ចេកទេស និង ថវិកា តាមរយៈគម្រោងបញ្ជ្រាបយេនឌ័រ ដំណាក់កាលទី២ (PGM2)។ ខ្ញុំក៏សូមសំដែងនូវការកោតសរសើរ នូវការបន្តខិតខំប្រឹងប្រែង និង ការចូលរួមចំណែកដ៏មានសារៈសំខាន់ របស់មន្ទីរកិច្ចការនារី មន្ទីរកសិកម្ម មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មន្ទីរអភិវឌ្ឍន៍ជនបទ មន្ទីរពាណិជ្ជកម្ម និងមន្ទីរផែនការ ក្នុងការអនុវត្តន៍សកម្មភាពរបស់គម្រោងសាកល្បងប្រកបដោយជោគជ័យ ដែលនេះជាមូលដ្ឋានដ៏ចាំបាច់នៃការចងក្រងសៀវភៅបច្ចេកទេសនេះឡើង។

ខ្ញុំមានជំនឿយ៉ាងមុតមាំថា សៀវភៅណែនាំបច្ចេកទេសចិញ្ចឹមមាន់នេះ នឹងត្រូវបានប្រើប្រាស់សម្រាប់ឆ្លើយតបទៅនឹងតម្រូវការចាំបាច់របស់ប្រជាកសិករ ជាពិសេសស្ត្រី ក្នុងការអនុវត្តន៍បច្ចេកទេសចិញ្ចឹមមាន់លក្ខណៈគ្រួសារប្រកបដោយជោគជ័យ ក្នុងគោលបំណងបង្កើនប្រាក់ចំណូលបន្ថែមសម្រាប់គ្រួសារ និង លើកកំពស់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី៕

**អភិបាលខេត្ត**

ហន់ លីមថៃ

# មាតិកា

ទំព័រ

**សារៈប្រយោជន៍ និង គោលការណ៍ទូទៅសំខាន់ៗ ៥យ៉ាង នៃការចិញ្ចឹមមាន់ ........ 1**
១. សារៈប្រយោជន៍នៃការចិញ្ចឹមមាន់លក្ខណៈគ្រួសារ........ 1
២. គោលការណ៍ទូទៅសំខាន់ៗ ៥យ៉ាង សម្រាប់ចិញ្ចឹមមាន់លក្ខណៈគ្រួសារ ........ 2
**គោលការណ៍ទី១ ការរៀបចំសម្ភារៈសម្រាប់ចិញ្ចឹមមាន់........ 3**
១.១ ទ្រុងកូនមាន់ ........ 3
១.២ ទ្រុងមាន់ធំ........ 4
១.៣ ទីធ្លាមានរបងព័ទ្ធជុំវិញ ........ 5
**គោលការណ៍ទី២ ការជ្រើសរើសពូជមាន់សុខភាពល្អ និង ផលិតភាពខ្ពស់ សម្រាប់ចិញ្ចឹម........ 7**
២.១ ពូជមាន់........ 7
២.២ ការជ្រើសរើសមាន់មានសុខភាពល្អ ........ 8
២.៣ របៀបបញ្ចូលពូជមាន់ថ្មី ជាមួយមាន់ដែលមានស្រាប់ ........ 8
២.៤ ការបំបែកមេបា សម្រាប់បង្កាត់ពូជ ........ 9
២.៥ ការដាក់មាន់គក និងមាន់មេអោយមានចំនួនសមាមាត្រ ........ 9
**គោលការណ៍ទី៣ ការរៀបចំចំណី និង ផ្តល់ចំណីមាន់ ........ 10**
៣.១ ចំណីមាន់........ 10
៣.២ របៀបផ្សំចំណី ........ 11
៣.៣ របៀបផ្តល់ចំណី និង ទឹក........ 12
៣.៤ របៀបធ្វើត្រីផ្អាប់........ 14
៣.៥ ការចិញ្ចឹមជន្លេនក្រហម ........ 15
៣.៦ ការដាំដំណាំចំណីសត្វ (ស្មៅ)........ 16
៣.៧ ការផ្តល់ចំណីបន្ថែម........ 17
**គោលការណ៍ទី៤ ការបង្ការមាន់ពីជំងឺឆ្លងសំខាន់ៗ........ 18**
៤.១ បុព្វហេតុបង្កជំងឺ........ 18
៤.២ របៀបបង្ការ និងព្យាបាល ........ 18
៤.៣ ជំងឺញូវកាសមាន់ ........ 19
៤.៤ ជំងឺអុតមាន់ ........ 21
៤.៥ ជំងឺអាសន្នរោគមាន់........ 24
៤.៦ ជំងឺផ្តាសាយបក្សី ........ 26
៤.៧ ជំងឺបង្កដោយបារ៉ាស៊ីត........ 28
៤.៨ តារាងកម្មវិធីធ្វើវ៉ាក់សាំងបង្ការជំងឺមាន់........ 30
៤.៩ វិធានការជីវសុវត្ថិភាព សម្រាប់បង្ការជំងឺមាន់........ 31

**គោលការណ៍ទី៥ ការធ្វើអនាម័យ និង ថែទាំមាន់** ..... 33
៥.១ អនាម័យសម្ភារៈចិញ្ចឹមមាន់ ..... 33
៥.២ ការចិញ្ចឹមមាន់ក្នុងទីធ្លាមានរបងព័ទ្ធជុំវិញ ..... 33
៥.៣ ការចិញ្ចឹមកូនមាន់ក្នុងទ្រុងតូច ..... 34
៥.៤ ការកំដៅកូនមាន់ដែលទើបញាស់ ..... 35
៥.៤ ការថែទាំមាន់មេបា ..... 36
៥.៥ ការរៀបចំកន្លែងសមស្របសម្រាប់មាន់ក្រាបពង ..... 36
៤.៦ វិធានការទប់ស្កាត់នៅពេលអាកាសធាតុត្រជាក់ និង ក្តៅ ..... 36
**តារាងកម្មវិធីធ្វើវ៉ាក់សាំង** ..... 37
**ការបង្កើនប្រាក់ចំណេញអតិបរមា** ..... 38
១. ពត៌មានទីផ្សារ ..... 38
២. ការវិភាគស្ថានភាពអាជីវកម្មចិញ្ចឹមមាន់ ..... 38
៣. ការរៀបចំយុទ្ធសាស្រ្តចិញ្ចឹមមាន់តាមរដូវកាល ..... 38
៤. ការសន្សំប្រាក់ ..... 39
**បទពិសោធន៍ នៃគម្រោងបញ្ញាបយេនឌ័រ ដំណាក់កាលទី២** ..... 40
១. សេចក្តីសង្ខេបស្តីពីគម្រោង ..... 40
២. ការណែនាំកសិករឲ្យអភិវឌ្ឍចិញ្ចឹមមាន់ជាជំហានៗ ..... 41
**បទពិសោធន៍ជោគជ័យ នៃក្រុមគោលដៅ គម្រោងបញ្ញាបយេនឌ័រ ដំណាក់កាលទី២** ..... 43
១. ករណី "ការបង្កើនប្រាក់ចំណូលតាមរយៈសកម្មភាពចិញ្ចឹមមាន់" ..... 43
២. ករណី "ការចិញ្ចឹមមាន់ពិតជាបានជួយឲ្យជីវភាពមានភាពប្រសើរឡើង" ..... 44
៣. ករណី "ការចូលរួមគាំទ្រពីសមាជិកគ្រួសារជាបុរស ក្នុងសកម្មភាពចិញ្ចឹមមាន់" ..... 45
៤. ករណី "មុខរបរចិញ្ចឹមមាន់ដែលទទួលបានជោគជ័យ" ..... 46
**សារៈសំខាន់ នៃទំនាក់ទំនងល្អក្នុងគ្រួសារ និង សង្គមដើម្បីចិញ្ចឹមមាន់ទទួលបានជោគជ័យ** ..... 47
១. ប្រពន្ធ ..... 47
២. ប្តី ..... 47
៣. កូន ..... 47
៤. ស្រ្តីមេម៉ាយ ..... 48

# សារៈប្រយោជន៍ និង គោលការណ៍ទូទៅសំខាន់ៗ ៥យ៉ាង នៃការចិញ្ចឹមមាន់

## ១. សារៈប្រយោជន៍នៃការចិញ្ចឹមមាន់លក្ខណៈគ្រួសារ




- **បង្កើនប្រាក់ចំណូលបន្ថែម ដោយមិនចាំបាច់បោះបង់មុខរបរមានស្រាប់**
  ការចិញ្ចឹមមាន់លក្ខណៈគ្រួសារ គឺមិនទាមទារពេលវេលាវែង ហើយកសិករអាចទទួលបានចំណូលបន្ថែម ដោយមិនចាំបាច់បោះបង់មុខរបរផ្សេងដែលមានស្រាប់នោះទេ ។
- **ប្រភពចំណូលមួយយ៉ាងទៀងទាត់**
  ការធ្វើស្រែ អាចទទួលបានផលតែមួយដង ឬពីរដងក្នុងមួយឆ្នាំ។ ការចិញ្ចឹមជ្រូកត្រូវការរយៈពេលវែង ដើម្បីអាចលក់បាន។ ផ្ទុយពីមុខរបរទាំងនោះ ការចិញ្ចឹមមាន់លក្ខណៈគ្រួសារ ផ្តល់នូវចំណូលមួយទៀងទាត់ ពីព្រោះមាន់ឆាប់ធំលឿនជាង និងងាយស្រួលលក់។ កសិករចិញ្ចឹមមាន់ជោគជ័យម្នាក់ បានប្រាប់ថា គាត់មានប្រាក់ សម្រាប់សងទៅធនាគារទាន់ពេល ដោយសារគាត់មានមាន់លក់ជារៀងរាល់ខែ ។
- **ចាប់ផ្តើមដោយប្រើប្រាស់ដើមទុនតិច**
  ការចិញ្ចឹមមាន់លក្ខណៈគ្រួសារមិនទាមទារដើមទុនច្រើននោះទេ កសិករអាចពង្រីកវាបានជាជំហ៊ានៗ ដោយប្រើប្រាស់ធនធានដែលខ្លួនមានស្រាប់។
- **ទទួលបានប្រាក់ចំណូល ដោយមិនចាំបាច់ស្វែងរកមុខរបរឆ្ងាយពីផ្ទះឡើយ**
  វាមិនងាយស្រួលទេ សម្រាប់កសិករក្នុងការស្វែងរកប្រាក់ចំណូលនៅឆ្ងាយពីផ្ទះ។ ពេលខ្លះ មានបញ្ហាប្រឈមជាច្រើនអាចកើតមានឡើង។ ការចិញ្ចឹមមាន់លក្ខណៈគ្រួសារ គឺផ្តល់ចំណូលមួយសមរម្យ និងឱកាសដល់សមាជិកគ្រួសាររស់នៅជួបជុំគ្នាទៀតផង។
- **ផ្តល់ឱកាសដល់ស្ត្រីចូលរួមរកប្រាក់ចំណូលសម្រាប់គ្រួសារ**
  មុខរបរចិញ្ចឹមមាន់ គឺផ្តល់ឱកាសដ៏ល្អ សម្រាប់ស្ត្រីចូលរួមក្នុងសកម្មភាពរកប្រាក់ចំណូលគ្រួសារ ដោយស្ត្រីអាចចិញ្ចឹមមាន់នៅផ្ទះ។

## ២. គោលការណ៍ទូទៅសំខាន់ៗ ៥យ៉ាង សម្រាប់ចិញ្ចឹមមាន់លក្ខណៈគ្រួសារ




<u>**គោលការណ៍ទី១: ការរៀបចំសម្ភារៈសម្រាប់ចិញ្ចឹមមាន់**</u>

កសិករត្រូវរៀបចំសំភារៈសម្រាប់ចិញ្ចឹមមាន់ ដូចជា ទ្រុងកូនមាន់ ទ្រុងមាន់ធំ និងទីធ្លាដែលមានរបងព័ទ្ធជុំវិញ ដើម្បីកាត់បន្ថយហានិភ័យ នៃជំងឺឆ្លង និងគ្រោះថ្នាក់ផ្សេងៗ។

<u>**គោលការណ៍ទី២: ការជ្រើសរើសមាន់សុខភាពល្អ និងផលិតភាពខ្ពស់ សម្រាប់ចិញ្ចឹម**</u>

កសិករត្រូវធ្វើការជ្រើសរើសមាន់មានសុខភាពល្អ និងមាឌធំដែលបានធ្វើវ៉ាក់សាំងត្រឹមត្រូវ។ ជ្រើសរើសពូជក្នុងស្រុក ដែលមានផលិតភាពខ្ពស់ សម្រាប់ចិញ្ចឹម។

<u>**គោលការណ៍ទី៣: ការផ្តល់ចំណីត្រឹមត្រូវ និងគុណភាពល្អ**</u>

កសិករត្រូវផ្តល់ចំណីដែលមានជីវជាតិ និងបរិមាណគ្រប់គ្រាន់ ដើម្បីអោយមាន់មានសុខភាពល្អ និង ធំធាត់លឿន។ ដើម្បីកាត់បន្ថយការចំណាយខ្ពស់លើការទិញចំណីសម្រេច កសិករអាចប្រើប្រាស់វត្ថុធាតុដើមដែលអាចរកបានជាមួយនឹងចំណីសម្រេច។ ការធ្វើត្រីផ្អាប់ ចិញ្ចឹមជន្លេន និងដាំស្មៅចំណីសត្វ អាចជួយឲ្យកសិករកាត់បន្ថយការប្រើប្រាស់ចំណីសម្រេចបាន ។

<u>**គោលការណ៍ទី៤: បង្ការមាន់ពីជំងឺឆ្លងសំខាន់ៗ**</u>

ការធ្វើវ៉ាក់សាំងបង្ការមាន់ពីជំងឺឆ្លងសំខាន់ៗ ៣ ប្រភេទរួមមាន ជំងឺញូវកាសមាន់ ជំងឺអុតមាន់ និង ជំងឺអាសន្នរោគមាន់ គឺវាមានសារៈសំខាន់ខ្លាំងណាស់។ ដើម្បីកាត់បន្ថយហានិភ័យនៃការឆ្លងជំងឺនានា កសិករត្រូវធ្វើការសម្លាប់មេរោគទាំងក្នុងទ្រុង និង ទីធ្លាចិញ្ចឹមអោយបានទៀងទាត់ ដោយប្រើប្រាស់វិធានការជីវសុវត្ថិភាព។ មួយវិញទៀត កសិករត្រូវយល់ដឹងពីវិធីជៀសវាងនៃការឆ្លងនៃជំងឺផ្តាសាយបក្សី ពីព្រោះវាជាជំងឺឆ្លងដ៏កាចសាហាវ អាចបង្កអោយមានគ្រោះថ្នាក់ដល់មនុស្សបាន។

<u>**គោលការណ៍ទី៥: ការថែទាំមាន់ជាប្រចាំ**</u>

កសិករទាមទារឲ្យយកចិត្តទុកដាក់ថែទាំមាន់ឲ្យបានល្អ ជាពិសេសមេមាន់កំពុងផ្តល់ស៊ុត និងកូនមាន់តូចៗ។

# គោលការណ៍ទី១
# ការរៀបចំសម្ភារៈសម្រាប់ចិញ្ចឹមមាន់

## ១.១ ទ្រុងកូនមាន់



ទំហំ និងកំពស់ទ្រុងកូនមាន់


ទ្រុងកូនមាន់ធ្វើអំពីឈើ និងឬស្សី


ឆ្នាំងដីសម្រាប់ដុតកំដៅកូនមាន់

- **មុខងាររបស់ទ្រុងកូនមាន់**

  ទ្រុងកូនមាន់ គឺជាប្រភេទទ្រុងមួយ សម្រាប់ដាក់កូនមាន់ដែលទើបញាស់ រហូតដល់អាយុ ១ខែ។

- **សារៈសំខាន់របស់ទ្រុងកូនមាន់**

  ទ្រុងកូនមាន់មានសារៈសំខាន់ សម្រាប់៖
  - ដាក់កូនមាន់ ដែលទើបនឹងញាស់
  - ការពារកូនមាន់ពីការបំផ្លាញរបស់សត្វចង្រៃ ដូចជា កណ្តុរ ពស់ ឆ្កែ ជាដើម
  - ងាយស្រួលធ្វើវ៉ាក់សាំង
  - ងាយស្រួលផ្តល់ទឹក និងចំណីឲ្យគ្រប់គ្រាន់

- **របៀបសង់ទ្រុងតូច**

  ទ្រុងកូនមាន់អាចសង់អំពីឈើ ឬស្សី និងសំណាញ់ ដោយអាស្រ័យលើធនធានដែលរកបាន។
  - ទ្រុងទំហំ ០.៨ម x ១.២ម អាចដាក់កូនមាន់បានចំនួនពី ២០ ទៅ ៣០ ក្បាល
  - ធ្វើទ្រនើរទ្រុងខ្ពស់ផុតពីដីតិចបំផុតកំពស់ ០.៤ម និងតួទ្រុងកំពស់ ០.៥ម
  - នៅពេលអាកាសធាតុត្រជាក់ ឬពេលយប់ ត្រូវរុំជុំវិញទ្រុងកូនមាន់ ដោយប្រើក្រណាត់ ឬសំបកបាវ ដើម្បីរក្សាកំដៅកូនមាន់ ជាពិសេសកូនមាន់ទើបនឹងញាស់។
  - ប្រើអង្កាមក្រាលបាតទ្រុង ដើម្បីរក្សាកំដៅកូនមាន់ និង កុំឲ្យទ្រុងមានសំណើម។

## ១.២ ទ្រុងមាន់ធំ

- **មុខងាររបស់ទ្រុងមាន់ធំ**

ទ្រុងមាន់ធំ មានមុខងារជាជំរកសម្រាប់មាន់ និង ដេក នៅពេលយប់។

- **សារៈសំខាន់ នៃទ្រុងមាន់ធំ**

ទ្រុងមាន់ធំ មានសារៈសំខាន់ សម្រាប់៖

- កាត់បន្ថយការចម្លងជំងឺ និងកត្តាបំផ្លាញផ្សេងៗ
- ការពារកំដៅ និង ទឹកភ្លៀង
- ផ្តល់ជំរក សម្រាប់មាន់ដេកពេលយប់
- ជាកន្លែង សម្រាប់មេមាន់ពង និងក្រាបពង
- ងាយស្រួលសំអាត និងប្រមូលលាមកមាន់
- ងាយស្រួលតាមដានសុខភាពមាន់ និងធ្វើវ៉ាក់សាំងជាដើម

- **ការជ្រើសរើសទីតាំងសង់ទ្រុងមាន់ធំ**

លក្ខណៈសមស្រប សម្រាប់សាងសង់ទ្រុងមាន់ធំគឺ៖

- ត្រូវសង់នៅកន្លែងដីទួល មិនលិចទឹក
- គួរសង់បែរទៅរកទិសដែលផ្តល់នូវ ពន្លឺព្រះអាទិត្យពេលព្រឹកគ្រប់គ្រាន់សម្រាប់មាន់
- គួរសង់នៅកន្លែងមានខ្យល់ចេញចូលល្អ
- គួរសង់នៅខាងក្រោយផ្ទះ និងឆ្ងាយពីផ្លូវធ្វើដំណើរ

- **សម្ភារៈសម្រាប់សង់ទ្រុងមាន់ធំ**

ដើម្បីកាត់បន្ថយការចំណាយ កសិករគួរប្រើប្រាស់ធនធានសម្ភារៈដែលមានស្រាប់ សម្រាប់សាងសង់ទ្រុងមាន់។

- សសរ និងរបារទ្រុង៖ កូនឈើ ដើមឬស្សី ពីងពង់
- ជញ្ជាំងទ្រុង៖ ធាងត្នោត ឬស្សី សំណាញ់
- ដំបូល៖ ស្លឹកត្នោត ស្បូវ ស្លឹកដូង ចំបើង

- **ទំហំ និងរបៀបសង់ទ្រុងមាន់ធំ**

- សង់ទ្រុងមាន់ មានទំហំ ២.៥ម x ៦ម អាចដាក់មេបាចំនួន ១០ក្បាល និងមាន់ជំទង់ចំនួន ៦០ក្បាល
- មេដំបូលគួរមានកំពស់ ៣ម និងជើងរៀងរបស់ទ្រុងកំពស់ ១.៧ម
- នៅខាងក្នុងទ្រុង កសិករគួរធ្វើទ្រនើរសងខាង កំពស់ ០.៨ម សម្រាប់មាន់ដេក និង រៀបចំដាក់សំបុកអោយផុតពីធ្នើរសម្រាប់មាន់ពង និង ក្រាបពង



ប្រភេទទ្រុងខ្នាតតូច



ប្រភេទទ្រុងមធ្យម



ទ្រនើរសម្រាប់មាន់ដេក



ផ្នែកខាងក្រោមនៃទ្រនើរ សម្រាប់មាន់លេង

- ប្រើប្រាស់អង្កាមក្រាលបាតទ្រុង ដើម្បីការពារសំណើម និងងាយស្រួលសំអាត

## ១.៣ ទីធ្លាមានរបងព័ទ្ធជុំវិញ

- **មុខងារ**

ទីធ្លាមានរបងព័ទ្ធជុំវិញ គឺជាកន្លែងសម្រាប់មាន់កកាយ និងរត់លេងតាមទំលាប់របស់វា ក្នុងគោលបំណងឲ្យមាន់មានសុខភាពល្អ។

- **សារៈសំខាន់ នៃរបងព័ទ្ធជុំវិញ**

ការរៀបចំទីធ្លាមានរបងព័ទ្ធជុំវិញ មានសារៈសំខាន់ដូចខាងក្រោម៖

- កាត់បន្ថយការចម្លងជំងឺពីមាន់ដទៃទៀតនៅក្នុងភូមិ
- ទីធ្លាចិញ្ចឹមអាចឲ្យមាន់កកាយ និងរកចំណីតាមទំលាប់របស់វា
- ងាយស្រួលថែទាំ ជាពិសេសទីធ្លាដែលមានខ័ណ្ឌចែកតាមអាយុមាន់ខុសៗគ្នា
- ជួយកាត់បន្ថយការចឹកគ្នា ប្រសិនបើទីធ្លាមានខ័ណ្ឌចែកតាមអាយុមាន់ខុសៗគ្នា

- **សារៈសំខាន់ នៃដំណាំទ្រើង**

- ដំណាំទ្រើង ដូចជា ននោង ឬត្រឡាច អាចដាំគ្របពីលើទីធ្លាចិញ្ចឹមមួយផ្នែក ដើម្បីផ្តល់ជាម្លប់សម្រាប់មាន់ជ្រក។
- ដំណាំបៃតង ដូចជា កន្ធំថេត ដំឡូងឈើ ជាដើម អាចដាំជុំវិញរបង និងសម្រាប់ជាម្លប់ផងដែរ។
- ដំណាំទ្រើង និងដំណាំបៃតង អាចផ្តល់ជាបន្លែសម្រាប់មាន់ទៀតផង។

- **សម្ភារៈសម្រាប់រៀបចំទីធ្លាចិញ្ចឹមមាន់**

ដើម្បីកាត់បន្ថយការចំណាយ កសិករគួរប្រើប្រាស់ធនធានមានស្រាប់ដូចជា៖

- កូនឈើ ឬស្សី ពីងពង់ ធាងត្នោត ជាដើម សម្រាប់ធ្វើជាសម្ភារៈសង់របង
- ដំណាំបៃតង រួមមាន ដើមដំឡូងឈើ កន្ធំថេត ជាដើម
- អាចប្រើសំណាញ់នីឡុង ឬសំណាញ់ដែក ជាដើម

- **របៀបធ្វើ និងរៀបចំទីធ្លាមានរបងព័ទ្ធជុំវិញ**

- ទីធ្លាគួរមានទំហំយ៉ាងតិច ៥មx៦ម សម្រាប់ដាក់មាន់មេបាចំនួន ១០ក្បាល រួមទាំងមាន់តូច និងមាន់ជំទង់ប្រមាណ ៦០ក្បាល
- ទីធ្លាត្រូវសង់នៅកន្លែងដីស្ងួត និងមិនលិចទឹក
- ទីធ្លាចិញ្ចឹមមាន់ត្រូវស្ថិតនៅកន្លែងឆ្ងាយពីផ្លូវដើរ និងទឹកកខ្វក់
- ទីធ្លាចិញ្ចឹមមាន់ត្រូវសង់កន្លែងមានខ្យល់ចេញចូលល្អ
- របងព័ទ្ធជុំវិញគួរមានកំពស់ ២ម ដើម្បីកុំអោយមាន់ហើរចេញបាន
- ដើម្បីកាត់បន្ថយការចម្លងជំងឺ ដូចជាជំងឺគ្រុនផ្តាសាយបក្សី ជាដើម កសិករគួរធ្វើសំណាញ់គ្របពីលើទីធ្លាចិញ្ចឹមមាន់ ដើម្បីការពារបក្សីហើរចូល
- ទីធ្លាចិញ្ចឹមគួរបែងចែកសម្រាប់មាន់ដែលមានអាយុខុសគ្នា ដូចទ្រុងមាន់ធំដែរ
- ជើងក្រោមនៃរបងដែលប្រើសំណាញ់ ត្រូវដាក់របាំងឬស្សី ដើម្បីការពារការបំផ្លាញពីសត្វចង្រៃ និងឆ្កែជាដើម



ទីធ្លាមានដំណាំទ្រើងគ្របពីលើ



របងដែលធ្វើទីដើមដំឡូងឈើនៅរស់



របងដើមដំឡូងឈើរស់ ផ្តល់ជាម្លប់សម្រាប់មាន់ជ្រក



បែងចែកទីធ្លាចិញ្ចឹមតាមអាយុខុសគ្នា



របងសំណាញ់ដែលមានរបាំងឬស្សីនៅជើងក្រោម



ទ្រនំ សម្រាប់មាន់លេង ក្នុងទីធ្លាចិញ្ចឹមមាន់



**គួរយល់ដឹង**

*កសិករមិនត្រូវដាក់ទា ក្នុងទីធ្លាចិញ្ចឹមជាមួយមាន់*
*ពីព្រោះទាអាចចម្លងជំងឺដល់មាន់បានយ៉ាងងាយ*

# គោលការណ៍ទី២
# ការជ្រើសរើសពូជមាន់សុខភាពល្អ និងផលិតភាពខ្ពស់ សម្រាប់ចិញ្ចឹម

## ២.១ ពូជមាន់

- **ពូជមាន់ក្នុងស្រុក**

ជាទូទៅ ពូជមាន់បាក្នុងស្រុករួមមាន់ មាន់ស្លួយ មាន់កណ្ដូង មាន់ប្រជល់ និងមាន់បង្កាត់ពូជក្នុងស្រុក និងមាន់មេក្នុងស្រុក រួមមាន មាន់សំពៅ មាន់ក្រញាស់ មាន់ចៃ និងមាន់បង្កាត់ក្នុងស្រុក។

គុណសម្បត្តិ នៃការចិញ្ចឹមមាន់ពូជក្នុងស្រុកគឺៈ

- ធន់ទ្រាំនឹងជំងឺ អាកាសធាតុ និងលក្ខខណ្ឌដទៃៗទៀត
- មិនចាំបាច់ផ្ដល់តែចំណីសម្រេច (មាន់ពូជក្នុងស្រុកអាចស៊ីចំណីផ្សំ ដែលមាននៅក្នុងភូមិ)
- ងាយស្រួលក្នុងការថែទាំ (ប្រើប្រាស់កំលាំងពលកម្មតិច និងរយៈពេលខ្លី)
- ផ្ដល់ពង និងចេះក្រាបពង និងបណ្ដើរកូនដោយខ្លួនឯង
- សាច់មាន់មានរស់ជាតិឆ្ងាញ់ តាមតម្រូវការក្នុងស្រុក
- ងាយស្រួលលក់ និងមានតម្លៃខ្ពស់ បើប្រៀបធៀបនឹងពូជមាន់នាំចូល



ពូជមាន់ក្នុងស្រុក

- **ពូជមាន់នាំចូល**

ជាទូទៅ ពូជមាន់នាំចូលគឺៈ

- ចិញ្ចឹមឆាប់ធំ ជាងមាន់ពូជក្នុងស្រុក
- ពិបាកថែទាំ និងងាយឆ្លងជំងឺ
- ស៊ីចំណីមានគុណភាពខ្ពស់ (ចំណីសម្រេច)
- ពិបាកលក់ និងមានតម្លៃថោកជាង មាន់ពូជក្នុងស្រុក



ពូជមាន់នាំចូល

## ២.២ ការជ្រើសរើសមាន់មានសុខភាពល្អ

- **របៀបជ្រើសរើសមេមាន់**



- មានទំងន់ចាប់ពី ១.៥គ.ក្រឡើង
- មានសុខភាពល្អ (មិនធ្លាប់ឆ្លងជំងឺ)
- ផ្តល់ពងលើសពី ១០ ឡើង និងផ្តល់ពងពី ៥ ទៅ ៦ ដង ក្នុងមួយឆ្នាំ
- ចេះក្រាបពង និងញាស់បានល្អ
- មានជើងព៌ណលឿង ដើម្បីងាយស្រួលលក់ និងតម្លៃខ្ពស់

- **របៀបជ្រើសរើសមាន់បា**



- មាន់បា ត្រូវមានមាឌធំ ដោយមានទំងន់យ៉ាងតិច ២គ.ក្រ
- មិនធ្លាប់ឆ្លងជំងឺ
- រហ័សរហួន (ពូកែជាន់មេ)
- មុខក្រហម និងភ្នែកភ្លឺថ្លា

- **របៀបជ្រើសរើសកូនមាន់**



- កូនមាន់ធ្វើវ៉ាក់សាំងរួច
- សុខភាពល្អ និងរហ័សរហួនដោយមានភ្នែកភ្លឺថ្លា
- មានអាយុប្រហាក់ប្រហែលគ្នា
- គូថស្ងួត (គ្មានរាគ)

## ២.៣ របៀបបញ្ចូលពូជមាន់ថ្មី ជាមួយមាន់ដែលមានស្រាប់

កសិករ ត្រូវដាក់ពូជមាន់ថ្មីជាមួយមាន់ដែលមានស្រាប់ អោយបានត្រឹមត្រូវ។ ប្រសិនបើមាន់ថ្មីនោះមានឆ្លងជំងឺ វាអាចឆ្លងដល់មាន់ដែលមានស្រាប់ ហើយពេលខ្លះ មាន់អាចស្លាប់ដោយសារការឆ្លងពីមាន់ដាក់ថ្មី។ ដូច្នេះ កសិករត្រូវប្រុងប្រយ័ត្ន ដោយជ្រើសរើសតែពូជមាន់ណាដែលមានសុខភាពល្អ និងគ្មានជំងឺ។ ទោះបីជាយ៉ាងណាក៏ដោយ វាមានការលំបាកដឹងណាស់ ថាតើពូជមាន់ថ្មីនោះមានឆ្លងជំងឺ ឬអត់។ ដូច្នេះ វិធីដែលងាយស្រួលបំផុតនោះគឺ ដាក់ពូជមាន់ថ្មី អោយនៅដាក់ដោយឡែក ក្នុងរយៈពេល ២ សប្តាហ៍។ បន្ទាប់ពីរយៈពេល ២សប្តាហ៍ ពូជមាន់ថ្មីមិនមានជំងឺឆ្លងទេ ទើបកសិករអាចបញ្ចូលពូជមាន់ថ្មីនោះចូលជាមួយ មាន់ដែលមានស្រាប់បានដោយសុវត្ថិភាព។



ពូជមាន់ថ្មី ត្រូវក្រុងបំបែកពីមាន់មានស្រាប់ ក្នុងរយៈពេល ២សប្តាហ៍

## ២.៤ ការបំបែកមេបា សម្រាប់បង្កាត់ពូជ

ការបែងចែកទីធ្លាដាក់ដោយឡែក សម្រាប់មាន់មេបា (មេមាន់ និងមាន់គក) គឺមានសារៈសំខាន់ដូចតទៅ៖

- ការពារការរំខានពីមាន់ដទៃទៀត ក្នុងពេលបង្កាត់ពូជ (ជាន់មេ)
- កសិករងាយស្រួលតាមដានថា តើមាន់កំពុងបង្កាត់ឬអត់
- ផ្តល់ចំណីសមស្របសម្រាប់មាន់មេបា កំពុងបង្កាត់ពូជ។ មាន់មេ ត្រូវការបរិមាណចំណីគ្រប់គ្រាន់ ពីព្រោះមាន់មេត្រូវផ្តល់ពងដែលអាចញាស់បាន ជាមួយលក្ខខណ្ឌសំបករឹងមាំល្អ។ ការផ្តល់ពពួកចំណីជាតិរ៉ែគឺមានសារៈសំខាន់ណាស់ សម្រាប់មាន់មេកំពុងផ្តល់ពង។ ស្របពេលជាមួយគ្នានោះ ការផ្តល់ចំណីដែលមានគុណភាព ដល់មាន់គក ក៏ជាកត្តាចាំបាច់ ពីព្រោះមាន់គកក៏ជាអ្នកផ្តល់នូវកំណើតដែលធ្វើអោយពងអាចមានលទ្ធភាពញាស់បានល្អ។

## ២.៥ ការដាក់មាន់គក និងមាន់មេអោយមានចំនួនសមាមាត្រ

- មាន់គក ១ ក្បាល អាចដាក់ជាមួយមាន់មេ ពី ៦ ទៅ ៧ ក្បាល
- កសិករមិនត្រូវដាក់មាន់គកលើសពី ១ ក្បាល ក្នុងទ្រុងខណ្ឌតែមួយ ជាមួយមាន់មេនោះទេ ពីព្រោះមាន់គកនឹងដេញជល់គ្នា នៅពេលបង្កាត់ពូជ ដែលជាហេតុធ្វើអោយពងមិនអាចញាស់បានទេ។ ប្រសិនបើកសិករមានមាន់គកពីរ កសិករអោយផ្លាស់ប្តូរគ្នា ទៅតាមវដ្តនៃការបង្កាត់ពូជនិមួយៗ។
- កសិករត្រូវប្តូរមេមាន់ថ្មី នៅពេលវាមានអាយុ ២ឆ្នាំ និង មាន់គក នៅពេលវាមានអាយុ ២.៥ឆ្នាំ (ពីរឆ្នាំកន្លះ) ពីព្រោះលទ្ធភាពផ្តល់ពង និងបង្កកំណើតមានការធ្លាក់ចុះ។



ដាក់មាន់គក ១ក្បាល ជាមួយមេមាន់ ៦ ទៅ ៧ ក្បាល ដោយខណ្ឌដាក់ពីមាន់ដទៃទៀត

# គោលការណ៍ទី៣
# ការរៀបចំចំណី និងផ្តល់ចំណីមាន់

## ៣.១ ចំណីមាន់

ចំណីដែលមានគុណភាពល្អ ជួយឲ្យមាន់មានសុខភាពល្អ និង ធំធាត់លឿន។ តាមតម្រូវការជីវជាតិ មាន់ត្រូវការចំណី ៤ ក្រុមសំខាន់ៗ ដូចជា ចំណីថាមពល ចំណីជាតិសាច់ ចំណីវីតាមីន និងចំណីជាតិរ៉ែ។ ការផ្សំចំណីដែលមានតុល្យភាពនៃក្រុមខាងលើ គឺជួយអោយមាន់មានសុខភាពល្អ និងលូតលាស់លឿន ។

- **ចំណីថាមពល**

មាន់ត្រូវការចំណីថាមពល សម្រាប់ផ្តល់កម្លាំង ក្នុងការធ្វើចលនា រំលាយអាហារ និងកត្តារស់នៅដទៃទៀត។ ប្រភេទចំណីថាមពលសំខាន់ៗរួមមាន៖




- **ចំណីជាតិសាច់**

វាជាប្រភេទចំណី ដែលត្រូវការសម្រាប់បង្កើតសាច់ ធ្វើអោយមាន់ឆាប់ធំធាត់ និងមានសាច់ច្រើន។ គំរូនៃប្រភេទចំណីនេះមាន៖




- **ចំណីវីតាមីន**

មាន់ត្រូវការចំណីវីតាមីន ដើម្បីបំពេញនូវមុខងារសរីរាង្គ។ មានចំណីវីតាមីនជាច្រើនប្រភេទ ងាយស្រួលរកបាន ដូចជា៖



- **ចំណីជាតិរ៉ែ**

ចំណីជាតិរ៉ែ ជួយឲ្យឆ្អឹងរឹងមាំ បង្កើតសំបកពង និងរក្សាលំនឹងក្នុងខ្លួនសត្វ។ ចំណីប្រភេទនេះ អាចរកបានដោយងាយ ដូចបង្ហាញខាងក្រោម៖

**ចំណីជាតិរ៉ែ**



អំបិល



សំបកខ្យង ឬ ខ្ចៅ



បុកវាឲ្យម៉ត់

## ៣.២ របៀបផ្សំចំណី



ការផ្សំចំណីសម្រាប់មាន់ធំ

ចំណីសម្រេច (ចំណីលក់នៅទីផ្សារ) មានតម្លៃថ្លៃណាស់ ។ ដើម្បីកាត់បន្ថយចំណាយលើចំណី កសិករអាចផ្សំចំណី ដែលអាចរកបានក្នុងបរិមាណច្រើន ដូចជា ស្រូវ កន្ទក់ ចុងអង្ករ ពោត និងសណ្តែក ដោយលាយ ជាមួយចំណីសម្រេចក្នុងបរិមាណសមស្រប។ សម្រាប់កូនមាន់ ដែលមានអាយុតិចជាង ៣០ថ្ងៃ កសិករគួរផ្តល់ចំណីសម្រេចអោយស៊ីតែម្តង ពីព្រោះវាធ្វើអោយកូនមាន់រឹងមាំ និង ធំធាត់លឿន។ ដើម្បីកាន់តែច្បាស់ សូមមើលអំពីរបៀបផ្តល់ចំណី និងទឹក ដោយព័ណនាលំអិតខាងក្រោម។



ចំណីសម្រេចផ្សំជាមួយចំណីរកបានក្នុងភូមិ (មុនពេលលាយ)

ចំណីសម្រេចផ្សំជាមួយចំណីរកបានក្នុងភូមិ (ក្រោយពេលលាយ)

## ៣.៣ របៀបផ្តល់ចំណី និង ទឹក

- **ចំណីកូនមាន់ (អាយុតិចជាង ៣០ថ្ងៃ)**
  - កូនមាន់ដែលទើបទំលាក់ពីសំបុក រហូតដល់ ៣០ថ្ងៃ គួរផ្តល់ចំណីសម្រេច (ដោយមិនចាំបាច់ផ្សំជាមួយ ចំណីដទៃទៀត)
  - កូនមាន់អាយុតិចជាង ៣០ថ្ងៃ ១ក្បាល ស៊ីចំណីប្រមាណ ២៥ ក្រាម ក្នុង ១ថ្ងៃ ដូច្នេះកូនមាន់ ១០ក្បាល ស៊ីចំណីប្រមាណ ២៥០ក្រាម (២ខាំ កន្លះ) ក្នុង ១ថ្ងៃ
  - កូនមាន់គួរផ្តល់ចំណី ៣ ទៅ ៤ ដង ក្នុង ១ថ្ងៃ
- **ចំណីមាន់ជំទង់ (អាយុ ៣០ - ៦០ថ្ងៃ)**
  - មាន់ជំទង់ គួរផ្តល់ចំណីសម្រេចត្រឹមតែ ៣០% ដោយលាយជាមួយវត្ថុធាតុដើមចំណីក្នុងស្រុក ៧០% ដូចជា កន្ទក់ ចុងអង្ករ ស្រូវ ពោត ចំណីវីតាមីន (ស្មៅ ត្រកួន ឬ ចក) និងចំណីជាតិរ៉ែ។ ចំណីវីតាមីន (ត្រកួន និងរុក្ខជាតិបៃតងដទៃទៀត) គួរលាយត្រឹមតែ ២០% ជាមួយចំណីសម្រេច។
  - មាន់ជំទង់ ១ក្បាល ស៊ីចំណីផ្សំប្រមាណ ៦០ក្រាម ក្នុង ១ថ្ងៃ ដូច្នេះមាន់ជំទង់ ១០ក្បាល ត្រូវការ ចំណីប្រមាណ ០.៦គ.ក្រ ក្នុង ១ថ្ងៃ។
  - គួរផ្តល់ចំណី ២ ទៅ ៣ដង ក្នុង ១ថ្ងៃ
- **ចំណីមាន់ធំ (អាយុ ៦០ថ្ងៃ-១២០ថ្ងៃ)**
  - មាន់ធំ គួរផ្តល់ចំណីសម្រេចប្រមាណ ៣០% និង ៧០% នៃចំណីរកបាន ដូចជា ស្រូវ ចុងអង្ករ កន្ទក់ ពោត ចំណីវីតាមីន និងចំណីជាតិរ៉ែ។ ចំណីវីតាមីន (ស្មៅ ត្រកូន ឬ ចក) គួរលាយត្រឹមតែ ២០% ជាមួយចំណីសម្រេច និងចំណីដទៃទៀត។
  - មាន់ធំ ស៊ីចំណីផ្សំប្រមាណ ១២០ក្រាម ក្នុង ១ថ្ងៃ ដូច្នេះ មាន់ធំ ១០ក្បាល ត្រូវការចំណីផ្សំ ១.២គ.ក្រ ក្នុង ១ថ្ងៃ
  - គួរផ្តល់ចំណីផ្សំ ២ ទៅ ៣ដង ក្នុង ១ថ្ងៃ
  - មាន់ធំ អាចផ្តល់ចំណីដែលកសិករអាចរកបានសុទ្ធ ដូចជាចំណីថាមពល ជាតិសាច់ វីតាមីន និងចំណីជាតិរ៉ែ ដោយផ្សំចូលគ្នា និងបរិមាណគ្រប់គ្រាន់។
- **ចំណីមាន់មេបា (អាយុចាប់ពី ១២០ថ្ងៃឡើង)**

  ជាធម្មតា កសិករអាចលក់មាន់ចាប់ពីអាយុ ១២០ថ្ងៃ (៤ខែ) ឡើង។ ប៉ុន្តែ មាន់មួយចំនួន ត្រូវរក្សាទុកដើម្បីធ្វើមេបន្ត ឬប្តូរមេចាស់ចេញ។ ជាទូទៅ មាន់មេ អាចផ្តល់ពង ចាប់ពីអាយុ ១៨០ថ្ងៃឡើង។
  - មាន់មេបា គួរផ្តល់ចំណីដូចមាន់ជំទង់ និងមាន់ធំដែរ ពោលគឺលាយចំណីសម្រេច ៣០% ជាមួយចំណីរកបាន ប្រមាណ ៧០%ទៀត។
  - មាន់មេបា ១០ ក្បាល ស៊ីចំណីផ្សំ ១.៥គ.ក្រ ក្នុង ១ថ្ងៃ
  - ការផ្តល់ចំណីជាតិរ៉ែ និងវីតាមីន មានសារៈសំខាន់ណាស់ សម្រាប់មាន់បង្កាត់ពូជ និងកំពុងផ្តល់ពង។

- **សម្ភារៈ សម្រាប់ផ្តល់ចំណី**

សម្ភារៈដាក់ចំណីសមស្រប និងការសំអាត គឺជាកត្តាសំខាន់ ក្នុងការចិញ្ចឹមមាន់។ ការផ្តល់ចំណី ជាមួយនឹងសម្ភារៈស្អាត អាចជួយកាត់បន្ថយការឆ្លងបរាសិតផ្សេងៗ។ សម្ភារៈដាក់ចំណីសមស្រប អាចជួយឲ្យមាន់ងាយស្រួលស៊ី និង ធ្វើឲ្យចំណីមានអនាម័យល្អ ពេលមាន់ស៊ី។ សម្ភារៈដាក់ចំណី អាចធ្វើបានដោយប្រើប្រាស់របស់ផ្សេងៗដែលមានស្រាប់ ដូចជា ឬស្សី សំបកកង់ឡានចាស់ៗ ធុងជ័រ ជាដើម។




សម្ភារៈដាក់ចំណីមិនសមស្រប (មាន់អាចកាយ និងធ្វើអោយខ្ចាយមកលើដី)




សម្ភារៈដាក់ចំណីត្រឹមត្រូវ (កសិករអាចការពារកុំអោយមាន់កាយចំណីបាន)

- **ការផ្តល់ទឹក**
  - ត្រូវផ្តល់ទឹកស្អាត សម្រាប់កូនមាន់ និងមាន់ធំ អោយមានជាប្រចាំក្នុងរយៈពេល ២៤ម៉ោង
  - មាន់ជំទង់ ឬមាន់មេបា ១០០ក្បាល ផឹកទឹកប្រមាណ៤លីត្រក្នុង១ថ្ងៃ (អាចប្រែប្រួលតាមអាកាសធាតុ)

ការផ្តល់ទឹកស្អាត និងសំអាតស្នូកទឹកជាប្រចាំ អាចជួយអោយមាន់មានសុខភាពល្អ និងមិនឆ្លងបរាសិតផ្សេងៗ។ ស្នូកទឹកត្រឹមត្រូវ ធ្វើអោយមាន់ងាយស្រួលផឹកទឹក និងធ្វើអោយទឹកមិនកខ្វក់។ ស្នូកទឹក អាចធ្វើពីរបស់មានស្រាប់ ដូចជា ដើមឬស្សី ដប/ធុងជ័រ និងរបស់ដទៃទៀត។







ស្នូកទឹកត្រឹមត្រូវ អាចការពារកុំអោយមាន់លោតចូល ដែលបណ្តាលអោយខ្វាយ និងកខ្វក់



**គួរយល់ដឹង** *កសិករ ត្រូវសំអាតស្នូកចំណី និងទឹកជារៀងរាល់ថ្ងៃ*

## ៣.៤ របៀបធ្វើត្រីផ្អាប់

- **សារៈប្រយោជន៍**
  - ធ្វើត្រីផ្អាប់ដោយប្រើប្រាស់ត្រីតូចៗ នៅរដូវត្រីថោក
  - អាចរក្សាទុកបានយូរ (ពី៦ ទៅ ១០ខែ)
  - កសិករអាចកាត់បន្ថយការទិញចំណីសម្រេច ដោយគ្រាន់តែលាយជាមួយចំណីអាចរកបានដទៃទៀតជាការស្រេច។
  - ត្រីផ្អាប់សំបូរដោយជាតិសាច់ ដែលធ្វើអោយមាន់ឆាប់ធំធាត់លឿន
- **សម្ភារៈសម្រាប់ធ្វើត្រីផ្អាប់៖** ថង់ប្លាស្ទិក និងធុងជ័រ និងវត្ថុធាតុដើមផ្សំ ដូចជា កូនត្រីតូចៗ ស្ករត្នោត កន្ទក់
- **របៀបធ្វើ**

កសិករ អាចធ្វើត្រីផ្អាប់តាមបរិមាណ ដែលខ្លួនអាចធ្វើបាន។ ដើម្បីធ្វើត្រីផ្អាប់ ១០០គ.ក្រ កសិករត្រូវអនុវត្តតាមរូបមន្តដូចបង្ហាញខាងក្រោម៖

(១)



ត្រី: ៥០គ.ក្រ

\+



ស្ករត្នោត: ១០គ.ក្រ

→



ប្រឡាក់ឲ្យសព្វ និង រក្សាទុករយៈពេល ១៥នាទី

(២)



ត្រីប្រឡាក់ជាមួយស្ករត្នោតបានសព្វល្អ

\+




កន្ទក់: ៤០គ.ក្រ

→



ប្រឡាក់ឲ្យសព្វជាមួយកន្ទក់

| | | | |
|---|---|---|---|
| (៣) | បន្ទាប់ពីប្រឡាក់កន្ទក់សព្វល្អ ច្រកវាចូលថង់ប្លាស្ទិក នៅក្នុងធុងជ័រ ឬ ពាង | <br>បង្ហាប់ត្រីឲ្យណែនល្អ និង បញ្ចេញខ្យល់កុំអោយមានក្នុងថង់ប្លាស្ទិក | <br>ចងថង់ឲ្យតឹង និងរក្សាទុកយ៉ាងតិច ២០ថ្ងៃ ទើបអាចយកឲ្យមាន់ស៊ីបាន |



**គួរយល់ដឹង** *ត្រូវបញ្ចេញខ្យល់ក្នុងថង់ប្លាស្ទិកអោយបានត្រឹមត្រូវ បើមិនដូច្នេះទេ ត្រីផ្អាប់នឹងខូច*

## ៣.៥ ការចិញ្ចឹមជន្លេនក្រហម

- **សារៈប្រយោជន៍នៃជន្លេនក្រហម**
  - ជន្លេនក្រហម ជាចំណីសំបូរជាតិសាច់ សម្រាប់មាន់ស៊ី និងឆាប់ធំធាត់
  - ចិញ្ចឹមជន្លេនក្រហមឲ្យមាន់ស៊ី ជួយកាត់បន្ថយការទិញចំណីសម្រេច
- **សម្ភារៈសម្រាប់ចិញ្ចឹមជន្លេនក្រហម**
  - សម្ភារៈដែលអាចរកបាន ដូចជា កូនឈើ ដើមឫស្សី និង ស្លឹកត្នោត ជាដើម អាចប្រើសម្រាប់សង់ទ្រុងចិញ្ចឹមជន្លេនក្រហម
  - ថង់ប្លាស្ទិក
  - លាមកគោស្រស់ ឬ កាកសំណល់ឡជីវឧស្ម័ន
- **របៀបចិញ្ចឹមជន្លេនក្រហម**

កសិករ អាចចិញ្ចឹមជន្លេនក្រហមនៅក្នុងរណ្តៅ ដែលអាចរៀបចំដូចខាងក្រោម៖

| | | |
|---|---|---|
| (១) |  | រណ្តៅជន្លេន ត្រូវសង់នៅកន្លែងមិនលិចទឹក និងគ្មានស្រមោច។ រណ្តៅចិញ្ចឹមជន្លេន គួរមានបណ្តោយ ៣ម ទទឹង ១ម និងកំពស់ ០.៤ម រួចក្រាលថង់ប្លាស្ទិក ឬចាក់បេតុងរឹង មានកំពស់ ០.៤ម ដើម្បីការពារស្រមោច។ |
| (២) |  | ដាក់លាមកគោស្រស់ ចូលទៅក្នុងរណ្តៅមានកំរាស់ ០.២ម និងស្រោចទឹកអោយសើមល្អ មុនដាក់ពូជជន្លេនចូល។ ពូជជន្លេនសម្រាប់ចិញ្ចឹម ត្រូវដាក់ក្នុងលាមកគោជាប្រចាំ (ជន្លេនអាចស្លាប់ បើគ្មានលាមកគោស្រស់ជាចំណី)។ លាមកក្របី ឬ ជ្រូក មិនល្អសម្រាប់ចិញ្ចឹមជន្លេនទេ ព្រោះជន្លេនមិនអាចរស់នៅ និងស៊ីវាបាន។ |

| | | |
|---|---|---|
| (៣) |  | រៀបចំដំបូលរណ្តៅជន្លេន ដើម្បីការពារទឹកភ្លៀង។ ជន្លេនក្រហមនឹងស្លាប់ ប្រសិនបើរណ្តៅលិចទឹក។ |
| (៤) |  | ត្រូវរក្សាសំណើមលាមកគោ ដោយស្រោចទឹកឲ្យសព្វជាប្រចាំ។ ជន្លេនក្រហមនឹងស្លាប់ ប្រសិនបើលាមកគោស្ងួត។ |
| (៥) |  | ចិញ្ចឹមរយៈពេល ២ខែ ដើម្បីអោយជន្លេនកើនច្រើន ទើបយកទៅឲ្យមាន់ស៊ី។ |



**គួរយល់ដឹង** *ត្រូវរក្សាសំណើមលាមកគោនៅក្នុងរណ្តៅជាប្រចាំ ដើម្បីអោយជន្លេនធំលឿន និងកើនបានច្រើន*

## ៣.៦ ការដាំដំណាំចំណីសត្វ (ស្មៅ)

- **សារៈប្រយោជន៍នៃស្មៅ**
  - ការដាំស្មៅ សម្រាប់ផ្សំជាចំណីមាន់ អាចជួយឲ្យកសិករកាត់បន្ថយការចំណាយ ទាំងពេលវេលា និងថវិកា ឬនៅពេលមិនអាចរកស្មៅបាននៅក្នុងភូមិ។
- **សម្ភារៈសម្រាប់ដាំស្មៅ**
  - ពូជស្មៅ ដែលមានឈ្មោះថា ម៉ូឡាតូ
- **របៀបដាំស្មៅ**

  ពូជស្មៅប្រភេទនេះ គឺងាយស្រួលដាំ ជាងបន្លែដទៃទៀត ដោយគ្រាន់តែដាំនៅជុំវិញផ្ទះជាការស្រេច។



ការដាំស្មៅ សម្រាប់ចជាចំណីមាន់

## ៣.៧ ការផ្តល់ចំណីបន្ថែម

- ចំណីបន្ថែម រួមមានថ្នាំគ្រាប់ ឬ ម្សៅវីតាមីន និងជាតិរ៉ែ សម្រាប់ផ្តល់ឲ្យមាន់ស៊ី។
- កសិករ មិនគួរផ្តល់ចំណីបន្ថែមទាំងនេះទៅឲ្យមាន់ ពីព្រោះវាមានការលំបាក ក្នុងការស្វែងរកប្រភេទថ្នាំដែលមានគុណភាពល្អ ប៉ុន្តែប្រសិនបើអាចរកបានថ្នាំត្រឹមត្រូវ និងគុណភាពល្អនោះ កសិករអាចផ្តល់ឲ្យមាន់ស៊ីបាន។
- កសិករ គួរផ្តល់ចំណីបន្ថែមទាំងនេះ ដោយប្រើប្រាស់ចំណីដែលអាចរកបានក្នុងភូមិ ដូចជារុក្ខជាតិបៃតង ឬពពួកចំណីជាតិរ៉ែដទៃ ជំនួសវិញ។

# គោលការណ៍ទី៤
# ការបង្ការមាន់ពីជំងឺឆ្លងសំខាន់ៗ

## ៤.១ បុព្វហេតុបង្កជំងឺ

មាន់មានសុខភាពមិនល្អដោយសារបុព្វហេតុ ៧យ៉ាងសំខាន់ៗដូចខាងក្រោម៖

- បង្កដោយមេរោគ (បាក់តេរី វីរុស ឬ ផ្សិត)
- រាតត្បាតដោយបរាសិត និង សត្វល្អិត
- បរិយាកាសរស់នៅមិនសមស្រប ដូចជា ទ្រុងចង្អៀតពេក ក្តៅខ្លាំង ភាពកខ្វក់ ។ល។
- ចំណីអាហារមិនគ្រប់គ្រាន់
- មាន់ស៊ីចំណីមានជាតិពុល
- សត្វមានពិសចឹក ឬខាំ
- គ្រោះថ្នាក់ផ្សេងៗ (ដូចជាម៉ូតូបុក)

## ៤.២ របៀបបង្ការ និងព្យាបាល

- **ការបង្ការជំងឺ**

កសិករ ត្រូវបង្ការមាន់មានសុខភាពល្អកុំឲ្យឆ្លងជំងឺ ដែលជាបុព្វហេតុនាំអោយមាន់ឈឺ។ មាន់ដែលឆ្លងជំងឺរួចហើយ គឺមានការលំបាកព្យាបាលអោយមានសុខភាពល្អដូចដើមណាស់។ ខាងក្រោមនេះ ជាវិធីសាស្រ្តក្នុងការបង្ការ និងទប់ស្កាត់ការឆ្លងជំងឺ៖

- ត្រូវចិញ្ចឹមមាន់ក្នុងទ្រុង ឬទីធ្លាចិញ្ចឹមមានរបងជានិច្ច ដើម្បីកុំឲ្យមាន់ដើរទៅកន្លែងកខ្វក់ ដែលបណ្តាលអោយឆ្លងមេរោគ ឬវីរុសផ្សេងៗ។
- ធ្វើវ៉ាក់សាំងមាន់ឲ្យបានត្រឹមត្រូវទៅតាមអាយុមាន់ (សំគាល់៖ វ៉ាក់សាំងមួយប្រភេទ អាចការពារជំងឺ បានតែមួយប្រភេទតែប៉ុណ្ណោះ)
- បំបែកមាន់មានផ្ទុកជំងឺ ឲ្យនៅដាច់ដោយឡែកពីមាន់មានសុខភាពល្អ (ហាមប៉ះពាល់មាន់ផ្ទុកជំងឺដោយផ្ទាល់ ជាពិសេស ត្រូវដាក់អោយឆ្ងាយពីកូនក្មេង)



ត្រូវបំបែកមាន់ដែលឆ្លងជំងឺ ឲ្យនៅឆ្ងាយពី មាន់មានសុខភាពល្អ

- ផ្តល់ចំណីអាហារមានជីវជាតិគ្រប់គ្រាន់ ដល់មាន់ដែលមានសុខភាពល្អ
- ត្រូវសម្លាប់ និងដុតមាន់ដែលបានឆ្លងជំងឺចោល ក្នុងករណីជាជំងឺធ្ងន់ធ្ងរ

- **ការព្យាបាលជំងឺ**

ជួនកាល មាន់អាចឈឺ ដូច្នេះកសិករត្រូវព្យាបាល ដោយព្យាយាមអោយមាន់មានសុខភាពល្អឡើងវិញ។ ខាងក្រោមនេះ ជាវិធីព្យាបាលមួយចំនួន ដែលកសិករអាចអនុវត្តបាន៖

- បំបែកមាន់មានផ្ទុកជំងឺ ឲ្យនៅដាច់ដោយឡែកពីមាន់មានសុខភាពល្អ (ហាមប៉ះពាល់មាន់ផ្ទុកជំងឺដោយផ្ទាល់ ជាពិសេស ត្រូវដាក់អោយឆ្ងាយពីកូនក្មេង)
- ផ្តល់ថ្នាំឲ្យបានត្រឹមត្រូវ តាមប្រភេទជំងឺមាន់
- ដាក់មាន់នៅកន្លែងមិនក្តៅពេក និងមានខ្យល់អាកាសចេញចូលល្អ




*កសិករត្រូវយល់ឲ្យច្បាស់ថា វ៉ាក់សាំង គឺសម្រាប់បង្ការជម្ងឺ រីឯ ឱសថ (ថ្នាំ) គឺសម្រាប់ព្យាបាលជំងឺ។ សូមកុំប្រើវ៉ាក់សាំង សម្រាប់ព្យាបាល ឬប្រើថ្នាំ សម្រាប់បង្ការជំងឺពីព្រោះវាអាចធ្វើឲ្យមាន់ក្លាយជាឈឺបាន។*

## ៤.៣ ជំងឺញូវកាសមាន់

- **បុព្វហេតុនៃជំងឺ**

ជំងឺញូវកាស គឺជាជំងឺមួយប្រភេទ ដែលនិយមកើតទៅលើសត្វមាន់នៅក្នុងប្រទេសកម្ពុជា ហើយវាធ្វើអោយអន្តរាយធ្ងន់ធ្ងរដល់មាន់ទៀតផង។ បុព្វហេតុនៃជំងឺនេះ គឺបង្កឡើងដោយមេរោគញូវកាសនៅក្នុងសារពាង្គកាយនៃសត្វមាន់។

ការឆ្លងមេរោគនេះ អាចកើតមានគ្រប់ពេលវេលា។ មាន់អាចចម្លងមេរោគនេះ ដោយសារប៉ះពាល់ជាមួយមាន់ដែលមានផ្ទុកជំងឺ។ មាន់ក៏អាចឆ្លងជំងឺនេះបាន ដោយសារការស៊ីចំណី ឬផឹកទឹកដែលមានប្រឡាក់ជាប់ដោយមេរោគញូវកាសប្រភេទនេះផងដែរ។ ជាទូទៅ ការផ្ទុះជំងឺនេះ គឺកើតឡើងនៅដើមរដូវក្ដៅ។ អត្រាមាន់ស្លាប់ គឺមានច្រើនរហូត ១០០ភាគរយតែម្ដង។

- **រោគសញ្ញា**

ជំងឺញូវកាសមាន់ មានរោគសញ្ញា ដូចខាងក្រោម៖

- ដង្ហក់ ក្អក និងកណ្ដាស់
- សំកុក ធ្លាក់ស្លាប អូសជើង រមួលក្បាល និងកទៅចំហៀង ប្រកាច់ អស់កំលាំង មិនស៊ីចំណី
- ពងថយចុះ ឬឈប់ពងតែម្ដង
- មានរាគពណ៌ខៀវ
- ហើមត្រង់ភ្នែក និងក
- មាន់ងាប់ច្រើន



រោគសញ្ញាមាន់ដែលកើតជំងឺញូវកាស (រមួលក)

- **ការព្យាបាលជំងឺ**

ជំងឺនេះមិនអាចព្យាបាលបានទេ កសិករអាចបង្ការមាន់ពីជំងឺនេះបានដោយប្រើវ៉ាក់សាំង និងវិធានការមួយចំនួនទៀត។

- **ការបង្ការជំងឺ**

- បន្តក់វ៉ាក់សាំងបង្ការជំងឺជាមុន
- បំបែកមាន់ផ្ទុកជំងឺ អោយនៅឆ្ងាយពីមាន់មានសុខភាពល្អ ដើម្បីការពារការឆ្លងបន្តទៅមាន់ផ្សេងទៀត
- សម្លាប់ ដុត និងកប់មាន់ដែលផ្ទុកជំងឺចោល (ហាមបរិភោគ ឬលក់មាន់ផ្ទុកជំងឺដាច់ខាត)
- សំអាត និងសំលាប់មេរោគដោយវិធានការជីវសុវត្ថិភាព
- ការពារកុំឲ្យមាន់ប៉ះពាល់ជាមួយបក្សីផ្សេងទៀត
- ហាមមិនឲ្យមនុស្សធ្វើដំណើរកាត់ទ្រុង ឬទីធ្លាចិញ្ចឹម (កសិករមិនត្រូវចូលទៅក្នុងទ្រុង ឬទីធ្លាចិញ្ចឹមប្រសិនបើមិនចាំបាច់ ឬពាក់ស្បែកជើងចូល ដើម្បីការពារការឆ្លងជំងឺនេះ)

- **របៀបធ្វើវ៉ាក់សាំងជំងឺញូវកាស**

កសិករ អាចធ្វើវ៉ាក់សាំងជំងឺញូវកាសដោយតាមវិធីដូចខាងក្រោម៖

(១)






ដបវ៉ាក់សាំង (ខាងមុខ) ដបវ៉ាក់សាំង (ខាងក្រោយ)

ផុតកំណត់ប្រើប្រាស់នៅថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១៤

ដបវ៉ាក់សាំង ដបទឹកលាយវ៉ាក់សាំង និងម្ជុលចាក់ថ្នាំត្រឹមត្រូវត្រូវមានលក្ខណៈដូចខាងក្រោម៖

- វ៉ាក់សាំង ត្រូវរក្សាទុកក្នុងធុង ឬ ទូទឹកកក ក្នុងសីតុណ្ហភាពចន្លោះ ២ ទៅ ៨ អង្សា
- វ៉ាក់សាំង មិនត្រូវផុតកំណត់កាលបរិច្ឆេទប្រើប្រាស់
- វ៉ាក់សាំងញូវកាសមាន ២ប្រភេទ គឺ អាយធូ និងញូវកាសអឹម។ កសិករ ត្រូវប្រើវ៉ាក់សាំងប្រភេទអាយធូ ដោយសារវ៉ាក់សាំងញូវកាសអឹម មិនអាចប្រើជាមួយកូនមាន់បានទេ
- ជាទូទៅ វ៉ាក់សាំង ១ ដបខ្នាតតូច អាចបន្តក់កូនមាន់បានចំនួន ២៥ ក្បាល ចំណែក ១ ដបខ្នាតកណ្តាល អាចបន្តក់កូនមាន់បានចំនួន ៥០ ក្បាល។ (សូមមើលសេចក្តីណែនាំបន្ថែម លើប្លាកសញ្ញា ដែលមានភ្ជាប់នៅលើសំបកដប)

(២)



- បន្តក់វ៉ាក់សាំងកូនមាន់ មានអាយុ ៣ ទៅ ៥ ថ្ងៃ ដែលមិនធ្លាប់ធ្វើកន្លងមក
- ត្រូវបន្តក់វ៉ាក់សាំង តែលើកូនមាន់មានសុខភាពល្អប៉ុណ្ណោះ

(៣)



បូមទឹកលាយពីដបប្លាស្ទិកអោយអស់ ដោយប្រើសឺរាំង រួចចាក់បញ្ចូលទៅក្នុងដបវ៉ាក់សាំង។ បន្ទាប់មក ក្រឡុកឲ្យសព្វល្អ។

(៤)



បូមល្បាយវ៉ាក់សាំងដែលបានក្រឡុងរួច ចូលទៅក្នុងសឺរាំងម្តងទៀត រួចហើយចាក់បញ្ចូលទៅក្នុងដបប្លាស្ទិកទទេវិញ

| | | |
|---|---|---|
| (៥) |  | - បន្តក់ទឹកវ៉ាក់សាំង ចំនួន ២ ដំណក់ ក្នុងមាត់កូនមាន់<br>- កូនមាន់ដែលបានបន្តក់វ៉ាក់សាំងរួច ត្រូវបំបែក ឬចំណាំ ជៀសវាងការធ្វើ ២ដង។ កូនមាន់បន្តក់ពីរដង អាច បណ្ដាលអោយឈឺ ឬងាប់បាន។ |
| (៦) |  | - វ៉ាក់សាំង មិនអាចរក្សាទុកខាងក្រៅធុង ឬទូទឹកកកបានទេ។ ប្រសិនបើទឹកវ៉ាក់សាំងមាននៅសល់ កសិករគួរចែកទៅអោយបងប្អូន ឬអ្នកជិតខាង។<br>- សឺរ៉ាំង និងម្ជុល មិនគួរប្រើម្ដងទៀតទេ ដូច្នេះសឺរ៉ាំង និងម្ជុលដែលនៅសល់ ត្រូវដុត និងកប់ចោល ក្នុងជំរៅយ៉ាងតិច ០.៤ម ។ សម្ភារៈសម្រាប់ប្រើប្រាស់ ត្រូវដាក់ឲ្យឆ្ងាយពីក្មេង។<br>- ដបវ៉ាក់សាំង និងដបប្លាស្ទិកត្រូវចោលក្នុងធុងសំរាម។ |

## ៤.៤ ជំងឺអុតមាន់

- **មូលហេតុបង្កជំងឺ**

ជំងឺអុតបក្សី គឺជាជំងឺឆ្លងមួយ ដែលតែងតែកើតមានលើមាន់នៅកម្ពុជា ហើយវាអាចបង្កអន្តរាយធ្ងន់ធ្ងរដល់ផលិតកម្មចិញ្ចឹមមាន់ទៀតផង។ មូលហេតុ នៃជំងឺនេះ គឺបង្កឡើងដោយមេរោគប្រភេទ វីរុស "អុត" ឆ្លងទៅមាន់ដទៃទៀត។

ការចម្លងមេរោគជំងឺនេះ អាចកើតមាននៅពេលមាន់មានសុខភាពល្អ ប៉ះពាល់ជាមួយមាន់មានផ្ទុកជំងឺអុតមាន់ស្រាប់។ មាន់អាចឆ្លងជំងឺនេះផងដែរ តាមរយៈការស៊ីចំណី និងផឹកទឹកជាមួយមាន់ឈឺ។ អត្រាងាប់មានកំរិតខ្ពស់ គឺ ១០ ទៅ ៩០ ភាគរយ។



កូនមាន់ដែលមានរោគសញ្ញាជំងឺអុតមាន់

- **រោគសញ្ញា**
  - ឬស្ស រីករាលដាលធំឡើងៗ និងក្រៀមជាក្រមរ នៅលើសិរ និងក្រោមរន្ធច្រមុះ
  - ពងខ្ទុះ ក្នុងមាត់ និងរន្ធច្រមុះ
  - ដំបៅលើស្បែក និងច្រមុះ
  - ខ្សោយកំលាំង និងមិនស៊ីចំណី (កូនមាន់ អាចងាប់ដោយសារមិនស៊ីចំណី)
  - ធំធាត់យឺត និងផ្តល់ពងតិច
  - មាន់ហៀរទឹកសំបោរ ចេញពីច្រមុះ និងហើមភ្នែក

- **ការព្យាបាល**

  រហូតមកដល់បច្ចុប្បន្ន មិនមានការព្យាបាលជំងឺអុតឲ្យជានោះទេ។ ជាមូលដ្ឋាន កសិករអាចបង្ការជំងឺអុតមាន់ប្រភេទនេះបាន ដោយការធ្វើវ៉ាក់សាំង។
- **ការបង្ការជំងឺអុតមាន់**
  - ធ្វើវ៉ាក់សាំងបង្ការជំងឺជាមុន
  - បំបែកមាន់មានផ្ទុកជំងឺ ចេញពីមាន់មានសុខភាពល្អ ដើម្បីកុំឲ្យឆ្លងបន្តទៅមាន់មានសុខភាពល្អ
  - សំលាប់ ដុត និងកប់មាន់ដែលផ្ទុកជំងឺចោល (ហាមដាច់ខាតហូបមាន់មានផ្ទុកជំងឺ)
  - ធ្វើអនាម័យ និងសំលាប់មេរោគដោយប្រើវិធានការជីវសុវត្ថិភាព
  - ការពារកុំឲ្យមាន់ប៉ះពាល់ជាមួយបក្សីផ្សេងទៀត
  - ហាមមិនឲ្យមនុស្សធ្វើដំណើរកាត់ទ្រុង ឬទីធ្លាចិញ្ចឹម (កសិករមិនត្រូវចូលទៅក្នុងទ្រុង ឬទីធ្លាចិញ្ចឹម ប្រសិនបើមិនចាំបាច់ ឬពាក់ស្បែកជើងចូល ដើម្បីការពារការឆ្លងជំងឺនេះ)
- **របៀបធ្វើវ៉ាក់សាំង**

  កសិករអាចធ្វើវ៉ាក់សាំងជំងឺអុតមាន់ តាមវិធីដូចខាងក្រោម៖

| | | |
|---|---|---|
| (១) | <br><br><br><br><br>ដបវ៉ាក់សាំង (ខាងមុខ) ដបវ៉ាក់សាំង (ខាងក្រោយ)<br>ផុតកំណត់ប្រើប្រាស់នៅថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៤ | ដបវ៉ាក់សាំង ដបទឹកលាយវ៉ាក់សាំង និងម្ជុលចាក់ថ្នាំត្រឹមត្រូវ ត្រូវមានលក្ខណៈដូចខាងក្រោម៖<br>- វ៉ាក់សាំង ត្រូវរក្សាទុកក្នុងធុង ឬទូទឹកកក ក្នុងសីតុណ្ហភាពចន្លោះ ២ ទៅ ៨ អង្សាសេ<br>- វ៉ាក់សាំង មិនត្រូវផុតកំណត់កាលបរិច្ឆេទប្រើប្រាស់<br>- វ៉ាក់សាំង ១ដប សម្រាប់កូនមាន់ ១០០ក្បាល |
| (២) |  | - ធ្វើវ៉ាក់សាំងកូនមាន់អាយុ ចន្លោះពី ១០ ទៅ ១៥ថ្ងៃ និងមិនធ្លាប់ធ្វើវ៉ាក់សាំងអុតកន្លងមក<br>- ធ្វើវ៉ាក់សាំងបានតែលើកូនមាន់មានសុខភាពល្អប៉ុណ្ណោះ |

| | | |
|---|---|---|
| (៣) |  | បូមទឹកលាយពីដបប្លាស្ទីក ចូលទៅក្នុងសីរ៉ាំង ចំនួន ៣ ម.ល |
| (៤) |  | ចាក់ទឹកលាយបញ្ចូលទៅក្នុងដបវ៉ាក់សាំង រួចហើយក្រឡុកអោយសព្វល្អ |
| (៥) |  | បើកគំរប ដែលបានក្រឡុកសព្វល្អនោះបន្ទាប់មកយកម្ជុលជ្រលក់ទឹកវ៉ាក់សាំង |
| (៦) |  | យកម្ជុលនោះ ចាក់លើបន្ទះស្លាបកូនមាន់។ កូនមាន់ដែលចាក់វ៉ាក់សាំងរួច ត្រូវចំណាំ ដោយបំបែកពីកូនមាន់ដែលមិនទាន់ធ្វើរួច ដើម្បីជៀសវាងការចាក់វ៉ាក់សាំងពីរដងលើកូនមាន់តែមួយ។ ការចាក់វ៉ាក់សាំងពីរដងអាចបណ្តាលអោយមាន់ឈឺ ឬ ងាប់បាន។ |

| | | |
|---|---|---|
| (៧) |  | - កសិករមិនអាចរក្សាទុកវ៉ាក់សាំងដោយគ្មានទូទឹកកកបានទេ។ ប្រសិនបើមានទឹកវ៉ាក់សាំងនៅសល់ កសិករគួរចែកទៅអោយបងប្អូន ឬអ្នកជិតខាង។<br>- សឺរាំង និងម្ជុល មិនគួរប្រើម្តងទៀតទេ ដូច្នេះសឺរាំង និងម្ជុលដែលនៅសល់ ត្រូវដុត និងកប់ចោល ក្នុងជំរៅយ៉ាងតិច ០.៤ម។ សម្ភារៈសម្រាប់ប្រើប្រាស់ ត្រូវដាក់ឲ្យឆ្ងាយពីក្មេង។<br>- ដបវ៉ាក់សាំង និងដបប្លាស្ទិកត្រូវចោលក្នុងធុងសំរាម<br>- ដបវ៉ាក់សាំង និងដបប្លាស្ទិកត្រូវចោលក្នុងធុងសំរាម |

## ៤.៥ ជំងឺអាសន្នរោគមាន់

- **បុព្វហេតុបង្កជំងឺ**

  ជំងឺអាសន្នរោគរោគមាន់ បង្កមកពីបាក់តេរី។ វាគឺជាជំងឺកាចសាហាវ និងរីករាលដាលខ្ពស់។ បុព្វហេតុចម្លងមកពីកន្លែងចិញ្ចឹមចង្អៀត ហើយមានមាន់ច្រើនពេក បរិស្ថានអាប់អួរ និងបណ្តាលមកពីមានការប៉ះពាល់ជាមួយបក្សីដែលផ្ទុកបាក់តេរី ឬស៊ីចំណី ផឹកទឹកដែលមានជាប់បាក់តេរី។ ជាទូទៅ ការផ្ទុះជំងឺ កើតឡើងនៅរដូវវស្សា និងអត្រាងាប់ខ្ពស់ រហូតដល់ ១០០% តែម្តង។

- **រោគសញ្ញា**
  - មាន់ថយកម្លាំង មិនស៊ីចំណី និង ពិបាកដកដង្ហើម
  - ហៀរសំបោរតាមច្រមុះ ភ្នែក និង មាត់
  - ក្អក បះរោម និង រាគមានលាយឈាម
  - ហើមត្រង់ណង់ សិរ និង មុខ បន្ទាប់មកឡើងព៌ណខៀវ
  - ហើមសន្លាក់ ដើបមិនកើត និងងាប់ភ្លាមៗ

- **ការព្យាបាល**

  កសិករអាចធ្វើការព្យាបាលជំងឺអាសន្នរោគមាន់បាន ដោយប្រើថ្នាំបំបាត់ការឈឺចាប់ និង អង់ទីប្យូទិចដ៍មានវិសាលភាព ប៉ុន្តែដំណើរការនៃការព្យាបាលមានការលំបាក និងស្មុគស្មាញ។ ដូច្នេះ កសិករគួរតែធ្វើការបង្ការជំងឺនេះដោយប្រើវ៉ាក់សាំង ប្រសើរជាងការព្យាបាលមាន់ដែលមានផ្ទុកជំងឺ។



**គួរយល់ដឹង** *កសិករត្រូវព្យាបាលមាន់ទាំងអស់ក្នុងហ្វូងដែលឆ្លងជំងឺ បើទោះបីជាមាន់ខ្លះនៅមានសុខភាពល្អក្តី ទើបទទួលបានលទ្ធផលល្អ*

- **ការបង្ការ**
  - ចាក់វ៉ាក់សាំងបង្ការ
  - ធ្វើអានាម័យ និង សំលាប់មេរោគនៅកន្លែងចិញ្ចឹមមាន់
  - ត្រូវដុតសាកសពមាន់ដែលឆ្លងជំងឺចោល
  - បំបែកមាន់ដែលឆ្លងជំងឺ ចេញពីមាន់មានសុខភាពល្អ
  - ហាមធ្វើដំណើរឆ្លងកាត់កន្លែងចិញ្ចឹមមាន់
  - ការពារសត្វកកេរ

- **របៀបចាក់វ៉ាក់សាំងបង្ការជំងឺអាសន្នរោគ**

កសិករអាចធ្វើវ៉ាក់សាំងជំងឺអាសន្នរោគមាន់ តាមលំដាប់លំដោយដូចខាងក្រោម៖

(១)



វ៉ាក់សាំង សឺរ៉ាំង និងម្ជុលចាក់ ដែលត្រឹមត្រូវគឺ

- ដបវ៉ាក់សាំងត្រូវរក្សាទុកនៅកន្លែងត្រជាក់ ដែលមានសីតុណ្ហភាពចន្លោះពី ២ ទៅ ៨ អង្សាសេ
- វ៉ាក់សាំង ១ដប មានចំណុះ ១០០ សេសេ ប្រើសម្រាប់មាន់ ១០០ក្បាល




ដបវ៉ាក់សាំង (ខាងមុខ)




ដបវ៉ាក់សាំង (ខាងក្រោយ)

ផុតកំណត់ប្រើប្រាស់នៅថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២៥៥៧ នៃឆ្នាំប្រតិទិនថៃ ឬ ត្រូវនឹងឆ្នាំ ២០១៤

(២)



ត្រូវចាក់វ៉ាក់សាំងមាន់ ដែលមានអាយុចន្លោះពី ៧ ទៅ ១០ សប្តាហ៍ និងមិនធ្លាប់ធ្វើវ៉ាក់សាំងកន្លងមក។ មាន់ដែលអាចធ្វើវ៉ាក់សាំងបាន ត្រូវមានសុខភាពល្អ។

(៣)



បូមវ៉ាក់សាំង ពីដបចូលក្នុងសឺរ៉ាំង ចំនួន ១ ម.ល សម្រាប់មាន់ ១ក្បាល

| | | |
|---|---|---|
| (៤) |  | ចាក់វ៉ាក់សាំង ១ ម.ល ទៅក្នុងសាច់ទ្រូងមាន់។ ត្រូវបំបែកមាន់ដែលចាក់រួច ពីមាន់ដែលមិនទាន់ធ្វើ ដើម្បីជៀសវាងចាក់វ៉ាក់សាំងជួនគ្នា។ ការចាក់វ៉ាក់សាំងពីរដង (ជួន) អាចបណ្តាលអោយមាន់ឈឺ ឬងាប់បាន។ |
| (៥) |  | វ៉ាក់សាំង ត្រូវរក្សាទុកក្នុងទូទឹកកកជាប្រចាំ។ ប្រសិនបើវ៉ាក់សាំងនៅសល់ កសិករគួរចែកអោយទៅបងប្អូន ឬអ្នកជិតខាង។<br>សឺរាំង និងម្ជុលប្រើរួច មិនគួរប្រើប្រាស់លើកក្រោយទេ។ ដូច្នេះ សឺរាំង និងម្ជុលត្រូវដុត និងកប់ចោលដោយប្រើកំបោរស ឬភ្លើង រួចកប់ក្នុងជំរៅ ៤០ ស.ម។<br>ដបវ៉ាក់សាំង ត្រូវចោលក្នុងធុងកាកសំណល់។ |



**គួរយល់ដឹង**

*កសិករអាចប្តូរពីឆ្នាំប្រតិទិនថៃ ទៅជាឆ្នាំគ្រឹស្តរាជ ដោយដកចំនួន ៥៤៣។ ឧទាហរណ៍: ឆ្នាំ ២៥៥៦ ដក ៥៤៣ គឺត្រូវនឹងឆ្នាំ ២០១៣*

## ៤.៦ ជំងឺផ្តាសាយបក្សី

- **ភាពគ្រោះថ្នាក់នៃជំងឺ**

ជំងឺផ្តាសាយបក្សី គឺជាជំងឺឆ្លងមួយប្រភេទ ដែលកម្រកើតមានចំពោះសត្វមាន់ណាស់។ តែទោះបីជាយ៉ាងណាក៏ដោយ កសិករត្រូវយកចិត្តទុកដាក់ និងប្រុងប្រយ័ត្នចំពោះជំងឺនេះ ព្រោះថាជំងឺនេះអាចចម្លងមកមនុស្សតាមរយៈសត្វស្លាបបាន ហើយវាបណ្តាលឲ្យមនុស្សងាប់បាន។ ជំងឺផ្តាសាយបក្សី មានលក្ខណៈខុសគ្នាពីជំងឺឆ្លងដទៃទៀត។



- **បុព្វហេតុបង្កជំងឺ**

  ជម្ងឺផ្តាសាយបក្សី អាចបណ្តាលអោយមាន់ឈឺ និងងាប់បានយ៉ាងឆាប់រហ័ស។ វីរុសអាចចម្លងទៅមនុស្សដោយការប៉ះពាល់ផ្ទាល់ជាមួយមាន់ ឬទាដែលផ្ទុកជំងឺ។ វាក៏អាចចម្លងដោយផ្ទាល់ពីលាមកសត្វ និងទឹកដែលមានមេរោគផងដែរ។

- **រោគសញ្ញា**

  ជំងឺនេះ អាចបង្ហាញរោគសញ្ញាផ្សេងៗជាច្រើន។ ពេលខ្លះ មាន់អាចងាប់ភ្លាមៗ ដោយគ្មានរោគសញ្ញាអ្វីទាំងអស់។

  ជាឧទាហរណ៍ រោគសញ្ញានៃជំងឺផ្តាសាយបក្សីរួមមាន៖

  - រាគរុះ
  - ហើមក្បាល ត្របកភ្នែក សិរ និង ណង់
  - ហៀរសំបោរ ក្អក កណ្តាស់ និងពិបាកដកដង្ហើម
  - សំកុក
  - ណង់ សិរ និង ជើងប្រែជាពណ៌ស្វាយ
  - ស្រកាទុន ឬ អាក់ពង និង ពងថយចុះ
  - បាក់កំលាំង និងមិនស៊ីចំណី



មាន់ងាប់ដោយសារជំងឺផ្តាសាយបក្សី

- **ការព្យាបាល**

  រហូតមកដល់បច្ចុប្បន្ន ជំងឺនោះមិនអាចព្យាបាលបានទេ។ ពេលជំងឺនេះផ្ទុះឡើង កសិករត្រូវរាយការទៅកាន់មន្ត្រីកសិកម្មស្រុកជាបន្ទាន់។ រដ្ឋាភិបាលត្រូវចាត់វិធានការណាមួយសមស្រប បើមិនដូច្នោះទេ កសិករនៅមូលដ្ឋាន នឹងប្រឈមទៅនឹងការចម្លងនៃជំងឺនេះ។

- **ការបង្ការសម្រាប់មាន់**

  កសិករត្រូវចិញ្ចឹមមាន់ក្នុងទីធ្លាចិញ្ចឹម ដែលមានរបងការពារ។ ប្រសិនបើកសិករបើកមាន់លែងក្រៅទ្រុង នោះមាន់នឹងប្រឈមនឹងការចម្លងជំងឺនេះពីមាន់ដទៃទៀត ឬ សត្វស្លាបព្រៃជាដើម។ ការអនុវត្តវិធានការជីវសុវត្ថិភាពត្រឹមត្រូវ គឺអាចការពារហានិភ័យ ដែលកើតឡើងដោយសារជំងឺផ្តាសាយបក្សីនេះបានខ្ពស់ បើទោះបីជាមិនបាន ១០០ភាគរយយ៉ាងណាក្តី។

- **ការបង្ការសម្រាប់មនុស្ស**

  - ហាមមិនអោយប៉ះពាល់ដោយផ្ទាល់ ជាមួយសាកសព លាមក ឬឈាមសត្វស្លាបដែលមានផ្ទុកជំងឺ។ ប្រសិនបើចាំបាច់ត្រូវតែប៉ះពាល់វា កសិករត្រូវប្រើទ្រនាប់ថងប្លាស្ទិក ដើម្បីកាន់។
  - កសិករមិនត្រូវប៉ះពាល់ជើង ស្រកាមាន់ ឬសម្ភារៈផ្ទះបាយ ដែលមានប៉ះពាល់ផ្ទាល់ជាមួយមាន់ផ្ទុកជំងឺនោះទេ។
  - កសិករត្រូវលាងដៃនឹងសាប៊ូជាប្រចាំ និងខ្ពុលមាត់ និងបំពង់ក ជាមួយទឹកស្អាត បន្ទាប់ពីធ្វើការជាមួយមាន់រួច។
  - ហាមកុំឲ្យក្មេង លេង ឬប៉ះពាល់មាន់ ទោះបីជាមាន់កំពុងមានសុខភាពល្អក៏ដោយ
  - កសិករត្រូវកាត់បន្ថយការប៉ះពាល់ផ្ទាល់ជាមួយមាន់ ជ្រូក និងសត្វស្លាបដែលមានជីវិត។
  - ហាមបរិភោគមាន់ងាប់ដោយជំងឺជាដាច់ខាត ព្រោះមានគ្រោះថ្នាក់ខ្លាំងណាស់។ មាន់ងាប់ ត្រូវដុត ឬ

កប់ចោលក្នុងដីដោយប្រើថង់ប្លាស្ទីករុំឲ្យជិតល្អ។

- ត្រូវចំអិតសាច់សត្វស្លាបឲ្យបានឆ្អិតល្អ ជាមួយកំដៅខ្ពស់

| | | |
|---|---|---|
|  |  |  |
| ហាមបរិភោគសត្វងាប់ដោយជំងឺ | ត្រូវពាក់ស្រោមដៃ និងម៉ាស់ជាប្រចាំ នៅពេលប៉ះពាល់មាន់ | ត្រូវលាងដៃជាមួយសាប៊ូជាប្រចាំ ក្រោយពេលធ្វើការជាមួយមាន់ |

## ៤.៧ ជំងឺបង្កដោយបរាស៊ីត

- **បុព្វហេតុបង្កជំងឺ**

បរាស៊ីត ជាប្រភេទសត្វល្អិតដូចជា ព្រូន ចៃ និងស្រមើល ដែលអាចរស់នៅក្នុងខ្លួនសត្វមាន់។ ជាធម្មតា ប្រភេទសត្វល្អិតទាំងនេះដែលកំពុងរស់នៅក្នុងលាមកសត្វ និងទឹកកខ្វក់ ប៉ុន្តែពួកវានឹងឡើងទៅនៅលើខ្លួនសត្វ ពេលវាស៊ី និងផឹកទឹកកខ្វក់នោះ។ បរាស៊ីត អាចរស់នៅ និងលូតលាស់នៅក្នុងខ្លួនសត្វមាន់ និងផ្តល់មកវិញនូវផលអាក្រក់ ដល់សុខភាពមាន់។

- **រោគសញ្ញា**
  - បះរោម និងរាគ ពេលខ្លះមានលាយឈាម
  - ធ្វើឲ្យខ្វាក់ភ្នែក (បរាស៊ីត អាចរស់នៅក្នុងភ្នែកមាន់ និងបណ្តាលអោយមាន់ខ្វាក់)
  - សំកុក ថយកម្លាំង និងមិនស៊ីចំណី
  - សិរ និង ណង់ស្លេកស្លាំង និងមុខមើលទៅមានសុខភាពមិនល្អ



មាន់មានបញ្ហាលើភ្នែក



បរាស៊ីត ដែលបានរកឃើញនៅក្នុងភ្នែកមាន់

- **ការព្យាបាល**

កសិករ អាចព្យាបាលជំងឺបរាស៊ីតដែលបានឆ្លងលើមាន់ ដោយប្រើថ្នាំទំលាក់សត្វល្អិត ដូចជា៖

- មេបង់ដាសុល/អាល់បង់ដាសុល ១គ្រាប់ (១ក្រាម) សម្រាប់មាន់ ១០ គ.ក
- ឡេវ៉ាមីសុល ១គ្រាប់ (១ក្រាម) សម្រាប់មាន់ ១០ គ.ក

កសិករអាចផ្តល់ថ្នាំទំលាក់បរាស៊ីត តាមដំណើរការដូចមានរៀបរាប់ខាងក្រោម។ មេបង់ដាសុល អាចរកទិញបានតែជាថ្នាំគ្រាប់ប៉ុណ្ណោះ។ ថ្នាំគ្រាប់ខ្លះមានទំងន់ ១ ក្រាម ហើយថ្នាំគ្រាប់ខ្លះមានទំងន់តែ ៥០០ ម.ក្រាម។ ចំណែក អាល់បង់ដាសុល និង ឡេវ៉ាមីសុល អាចរកទិញបាន ជាកញ្ចប់ម្សៅ។ មានផលិតផលខុសៗគ្នា ប៉ុន្តែមានប្រសិទ្ធភាពប្រហាក់ប្រហែលគ្នា សម្រាប់ទំលាក់សត្វល្អិត។

រូបភាពបង្ហាញខាងក្រោមនេះ ជាគំរូមួយនៃការអនុវត្តរបស់ អាល់បង់ដាសុលះ

| | | |
|---|---|---|
| (១) | <br>កាលកំណត់បរិច្ឆេទប្រើប្រាស់ អាចមើលលើប្រអបង់ តែមិនមាននៅលើកញ្ចប់ថ្នាំនោះទេ | នៅលើប្រអប់ធំ កសិករអាចរកមើលកាលបរិច្ឆេទប្រើប្រាស់បាន។ កញ្ចប់ម្សៅនេះ មានបរិមាណ ៥ ក្រាម។ |
| (២) |  | រៀបចំទឹក មានចំណុះ 0.៥ លីត្រ (កន្លះលីត្រ)ដាក់ក្នុងដប រួចហើយចាក់ម្សៅថ្នាំចូលក្នុងដបទឹកនោះ។ |
| (៣) |  | ក្រឡុកដបនោះ រហូតម្សៅថ្នាំរលាយសព្វជាមួយទឹកល្អ |
| (៤) |  | ចាក់ទឹកលាយម្សៅថ្នាំនោះ តាមសមាមាត្រចំនួនមាន់ដែលបានបញ្ជាក់ខាងលើ។ |



**គួរយល់ដឹង** *កសិករគួរដាក់ថ្នាំទំលាក់បារាស៊ីត ជារៀងរាល់ខែ សម្រាប់មាន់មានអាយុចាប់ពី ១ខែ កន្លះឡើង*

- **ការបង្ការជំងឺបារាស៊ីត**
  - សំអាតទ្រុងមាន់ និងទីធ្លាចិញ្ចឹមមាន់ជាប្រចាំ
  - ផ្តល់ចំណី និងទឹកមានអនាម័យ

- ផ្ដល់រុក្ខជាតិឱសថអោយមាន់ ដូចជាស្លឹកស្ដៅ គ្រាន់កន្ទំថេត ស្លាខ្ទី ជាដើម។ កសិករអាចជញ្ជ្រាំ បុក ឬ កិនអោយម៉ត់ និងលាយជាមួយចំណី ក្នុងបរិមាណ ៥ ភាគរយនៃចំណីសរុប។ កសិករ អាច ផ្ដល់រុក្ខជាតិឱសថទាំងនេះអោយមាន់ស៊ីរៀងរាល់ខែ។ តែទោះបីជាយ៉ាងណា រុក្ខជាតិឱសថទាំងនេះ គួរប្រើប្រាស់នៅពេលណា ដែលមិនអាចរកថ្នាំម្សៅស្រាប់លើទីផ្សារបាន។ រុក្ខជាតិឱសថទាំងនេះ ខ្លះ មិនអាចមានប្រសិទ្ធភាពសម្រាប់ទំលាក់បរាស៊ីតប្រភេទខ្លះបានទេ។



ស្លឹកកន្ទំថេត



ស្លឹកស្ដៅ

## ៤.៨ តារាងកម្មវិធីធ្វើវ៉ាក់សាំងបង្ការជំងឺមាន់

ដើម្បីបង្ការមាន់ ពីជំងឺឆ្លងសំខាន់ៗទាំងបីខាងលើ កសិករគួរអនុវត្តធ្វើវ៉ាក់សាំងតាមតារាងដូចខាងក្រោម៖

| ជំងឺសំខាន់ៗ | អាយុមាន់ត្រូវធ្វើវ៉ាក់សាំង | ប្រសិទ្ធភាពវ៉ាក់សាំង | វិធីធ្វើវ៉ាក់សាំង | កម្រិតថ្នាំ |
|---|---|---|---|---|
| ញូវកាស | - លើកទី១: ៣-៥ ថ្ងៃ<br>- លើកទី២: ៣-៤សប្ដាហ៍ | រយៈពេលបាន ៦ខែ សម្រាប់ញូវកាសប្រភេទអាយធូ បន្ទាប់ពីធ្វើវ៉ាក់សាំងរំលឹកលើកទី២ | បន្តក់ទឹកវ៉ាក់សាំងតាមមាត់មាន់ | ២ តំណក់ |
| អុតបក្សី | ១០-១៥ ថ្ងៃ (ធ្វើវ៉ាក់សាំងមាន់អាយុលើសពី ៣សប្ដាហ៍ គឺមិនមានប្រសិទ្ធភាពទេ) | មួយជីវិតមាន់ | ចាក់លើបន្ទះស្លាប | ៣ ម.ល |
| អាសន្នរោគ | ៧-១០ សប្ដាហ៍ (អាចធ្វើបានគ្រប់ពេល បន្ទាប់ពីមាន់មានអាយុចាប់ពី ១០សប្ដាហ៍ឡើង) (សម្រាប់មាន់មេបា ត្រូវធ្វើដោយឡែក ជារៀងរាល់ ៦ខែម្ដង) | ៦ ខែ | ចាក់លើសាច់ទ្រូង | ១ ម.ល |



**គួរយល់ដឹង**

*វ៉ាក់សាំង ១ដប សម្រាប់មាន់ជាច្រើន*

*ដូច្នេះកសិករគួរស្វែងរកកសិករជិតគ្នាដែលមានមាន់អាយុប្រហាក់ប្រហែលគ្នា ដើម្បីធ្វើវ៉ាក់សាំងចូលគ្នា។*

## ៤.៩ វិធានការជីវសុវត្ថិភាព សម្រាប់បង្ការជំងឺមាន់

- **ភាពទូទៅ**

  កសិករ អាចសម្លាប់ប្រភេទវីរុសចង្រៃនៅក្នុងទ្រុង ក្រៅទ្រុង និង ទីធ្លាចិញ្ចឹមមាន់បានដោយប្រើវិធានការជីវសុវត្ថិភាព។ មានវិធានការជីវសុវត្ថិភាព ២ យ៉ាងសំខាន់ៗ គឺការបាញ់ថ្នាំសម្រាប់សម្លាប់មេរោគ និង ការបាចកំបោរស។

- **ការបាញ់ថ្នាំសម្លាប់មេរោគ**

  ការបាញ់ថ្នាំសម្លាប់មេរោគ គឺធ្វើឡើងខាងក្នុង និងខាងក្រៅទ្រុង និងក្នុងទីធ្លាចិញ្ចឹមមាន់ ដោយបាញ់ទឹកលាយថ្នាំ ប្រភេទ បេ-កា-អា (B-K-A) ឬ ហ្វម៉េត (Formades)។ កសិករអាចបាញ់ថ្នាំសម្លាប់មេរោគតាមដំណើរការដូចបង្ហាញខាងក្រោម៖




បេ-កា-អា ត្រូវលាយជាមួយទឹកចំនួន ១០០ដង។ មានន័យថា ថ្នាំ ១ ម.ល លាយជាមួយទឹក ១ លីត្រ




ហ្វម៉េត ត្រូវលាយជាមួយទឹកចំនួន ២៥០ដង។ មានន័យថា ថ្នាំ ១ម.ល ត្រូវលាយជាមួយទឹក ២.៥ លីត្រ

| | | |
|---|---|---|
| (១) |  | មានថ្នាំសម្លាប់មេរោគ បេ-កា-អា ឬ ហ្វម៉េត ស្នប់បាញ់ថ្នាំ ធុងលាយថ្នាំ ម៉ាស់បិទមុខ និង ស្រោមដៃ។ |
| (២) |  | ប្រើស្រោមដៃ និង ម៉ាស់បិទបិទមុខ ដើម្បីការពារសុខភាពកសិករខ្លួនឯង |

| | | |
|---|---|---|
| (៣) |  | ប្រើសីរ៉ាំង បូមថ្នាំទឹកចំនួន ១ សេសេ (ម.ល) រួចបាញ់បញ្ចូលក្នុងធុងទឹកដែលរៀបចំស្រេច។ សំគាល់៖ ទឹកថ្នាំ បេ-កា-អា ១សេសេ (ម.ល) ត្រូវលាយជាមួយទឹក ១លីត្រ ចំណែក ថ្នាំហ្វម៉េត ១សេសេ ត្រូវលាយជាមួយ ទឹក ២,៥ លីត្រ (២លីត្រកន្លះ) |
| (៤) |  | លាយវាឲ្យសព្វល្អ ដោយកូរ បន្ទាប់មកបូមចូលក្នុងស្នប់ |
| (៥) |  | បាញ់ថ្នាំនោះ នៅក្នុង និង ខាងក្រៅទ្រុងតូច និងធំ និង បរិវេណទីធ្លាចិញ្ចឹមមាន់។ ហាមបាញ់ថ្នាំសម្លាប់មេរោគនេះ លើមាន់ផ្ទាល់ ព្រោះបណ្តាលឲ្យមាន់ឈឺបាន។ |
| (៦) |  | - ស្នប់ ធុងទឹក និង សំភារៈដទៃទៀត ត្រូវលាងទឹកឲ្យស្អាតបន្ទាប់ពីប្រើប្រាស់រួច។<br>- កសិករត្រូវរក្សាទុកស្នប់បាញ់ថ្នាំ និង ដបថ្នាំនៅសល់ នៅកន្លែងខ្ពស់ផុតពីដៃក្មេង។ |

- **ការបាចកំបោរស សម្លាប់មេរោគ**

កសិករក៏អាចសម្លាប់មេរោគដោយបាចកំបោរស មុនពេលដាក់មាន់ថ្មីចូលក្នុងទ្រុង។ ទីធ្លាចិញ្ចឹមមាន់ក៏គួរបាចកំបោរដើម្បីសម្លាប់មេរោគ មុនពេលចាប់ផ្តើមចិញ្ចឹមមាន់ដែរ ឬបាចវានៅពេលមានជំងឺផ្ទុះឡើង។ ត្រូវប្រើរយៈពេល ២ សប្តាហ៍ និង បោសសំអាតកំបោរចេញឲ្យស្អាត មុនពេលដាក់មាន់ចិញ្ចឹម។ កំបោរ មាន ២ប្រភេទ គឺកំបោរហុយ និងកំបោររាវ។ សម្រាប់កំបោររាវ កសិករគ្រាន់តែលាយជាមួយទឹក រួចហើយប្រើតែម្តង ជាការស្រេច។



ការបាចកំបោរសម្លាប់មេរោគ



**គួរយល់ដឹង**

*កសិករត្រូវរក្សាធុងលាយទឹកកំបោរ ស្នប់បាញ់ និងបាចកំបោរ ឲ្យផុតពីដៃក្មេង ការពារកុំឲ្យក្មេងលេង ព្រោះវាបណ្តាលអោយប៉ះពាល់ដល់សុខភាពពួកគេ*

# គោលការណ៍ទី ៥
# ការធ្វើអនាម័យ និង ថែទាំមាន់

## ៥.១ អនាម័យសម្ភារៈចិញ្ចឹមមាន់

សម្ភារៈចិញ្ចឹមមាន់ ត្រូវការសំអាតជាប្រចាំ ដើម្បីឲ្យមាន់មានសុខភាពល្អ។ បើមិនមានអនាម័យនោះទេ នោះមាន់នឹងប្រឈមនឹងបញ្ហាជាច្រើន ដែលនាំឲ្យប៉ះពាល់ផលប្រយោជន៍ដល់កសិករខ្លួនឯង។ ការធ្វើអនាម័យសម្ភារៈដាក់ចំណី និង ទឹក គឺជាកត្តាសំខាន់ ក្នុងនោះទីធ្លាចិញ្ចឹមមាន់ក៏ត្រូវទាមទារការសំអាតផងដែរ។ កសិករ ទាមទារពេលវេលាប្រហែលជា ៣០នាទីតែប៉ុណ្ណោះ ដើម្បីសំអាតសំភារៈទាំងនោះ។



ទិដ្ឋភាពទ្រុងដែលមានអនាម័យ



ការសំអាតសម្ភារៈដាក់ចំណី និងទឹក

## ៥.២ ការចិញ្ចឹមមាន់ក្នុងទីធ្លាមានរបងព័ទ្ធជុំវិញ

- **អត្ថប្រយោជន៍នៃការចិញ្ចឹមមាន់ក្នុងទីធ្លាមានរបង**

  កសិករ ត្រូវចិញ្ចឹមមាន់ក្នុងទីធ្លាមានរបងព័ទ្ធជុំវិញជាប្រចាំ ពីព្រោះ៖

  - បង្ការមាន់កុំឲ្យឆ្លងជំងឺពីសត្វ និងបរិស្ថានខាងក្រៅ
  - កសិករងាយស្រួលគ្រប់គ្រង រួមទាំងដឹងពីចំនួនមាន់ពិតប្រាកដ ដែលធ្វើអោយងាយស្រួលក្នុងការធ្វើផែនការចិញ្ចឹមបានប្រសើរទៀតផង

  កសិករ ត្រូវអនុវត្តការចិញ្ចឹមក្នុងទីធ្លាមានរបងព័ទ្ធជុំវិញ ដើម្បីបញ្ចៀសការចម្លងជំងឺផ្សេងៗ។ ជំងឺឆ្លងអាចធ្វើអោយមាន់ងាប់ និង ប៉ះពាល់ដល់សុខភាពខ្លួនឯងផងដែរ។

- **ការបំបែកទា និងសត្វចិញ្ចឹមដទៃចេញពីមាន់**

  កសិករ ត្រូវបំបែកទា និងសត្វចិញ្ចឹមដទៃទៀតអោយដាច់ដោយឡែកពីមាន់។ មានន័យថា មិនត្រូវដាក់ទា និង សត្វចិញ្ចឹមផ្សេងទៀតចូលក្នុងទ្រុង ឬ ទីធ្លាជាមួយមាន់ឡើយ។ ទា ជាភ្នាក់ងារចម្លងវីរុសមួយដល់មាន់ ពីព្រោះទាអាចផ្ទុកជំងឺបានយូរជាងមាន់។

- **ការដាក់មាន់តាមចំនួនសមមាត្រនឹងទ្រុង**

  កសិករត្រូវដាក់មាន់ឲ្យសមមាត្រនឹងទំហំរបស់ទ្រុង។ ទ្រុងមាន់ទំហំ ១០ម៉ែត្រការ៉េ ត្រូវដាក់មាន់ធំមិនឲ្យលើសពី ១៥ ក្បាល។ សម្រាប់មាន់មេបា ត្រូវការទំហំទីធ្លាធំជាងនេះទៀត គឺ ១០ម៉ែត្រការ៉េ ដាក់បានចំនួន ១០ក្បាលប៉ុណ្ណោះ។ មាន់នឹងងាយឆ្លងជំងឺ ពេលរស់នៅក្នុងទីធ្លាចង្អៀតពេក។



ការចិញ្ចឹមមាន់ក្នុងទីធ្លាមានរបងព័ទ្ធជុំវិញ



ទ្រុងមាន់មានរបង សម្រាប់ចិញ្ចឹមមាន់

## ៥.៣ ការចិញ្ចឹមកូនមាន់ក្នុងទ្រុងតូច

- **អត្ថប្រយោជន៍នៃការចិញ្ចឹមកូនមាន់ក្នុងទ្រុងតូច**

  មានហេតុផលជាច្រើន ដែលទាមទារឲ្យកសិករដាក់កូនមាន់ចិញ្ចឹមក្នុងទ្រុងតូចជានិច្ចៈ

  - បង្ការកូនមាន់កុំឲ្យឆ្លងជំងឺពីសត្វ និង បរិស្ថានខាងក្រៅ
  - ងាយស្រួលការពារកូនមាន់ពីការបំផ្លាញពីសត្វដទៃ
  - ងាយស្រួលថែទាំពីបរិស្ថានខាងក្រៅ ដូចជាការពារកុំឲ្យត្រូវភ្លៀង កំដៅខ្លាំងពេក និង គ្រោះថ្នាក់ផ្សេងៗទៀត។
  - ងាយស្រួលក្នុងការធ្វើវ៉ាក់សាំង និង ការថែទាំដទៃទៀត
  - ជួយកាត់បន្ថយការបាត់កូនមាន់ ជាទូទៅការចិញ្ចឹមក្នុងទ្រុងតូច កូនមាន់អាចរស់យ៉ាងតិចបំផុត ៨០ ភាគរយ (មានន័យថា កូន ១០ក្បាល អាចរស់បានចំនួន ៨ក្បាល)។

- **ការដាក់កូនមាន់តាមចំនួនសមមាត្រនឹងទ្រុង**

  កសិករត្រូវដាក់កូនមាន់តាមចំនួនសមមាត្រនឹងទំហំទ្រុង។ ទំហំទ្រុងតូច ១ ម៉ែត្រការ៉េ ត្រូវដាក់កូនមាន់ មិនឲ្យលើសពី ១០ក្បាល។



ការចិញ្ចឹមកូនមាន់ក្នុងទ្រុងតូច



កូនមាន់ចិញ្ចឹមនៅក្នុងទ្រុងតូច

## ៥.៤ ការកំដៅកូនមាន់ដែលទើបញាស់

កូនមាន់ដែលទើបនឹងញាស់ រហូតដល់អាយុ ៣ សប្តាហ៍ ត្រូវការកំដៅខ្ពស់។ ដូច្នេះកសិករត្រូវអង្កេតមើលថាតើអាកាសធាតុខាងក្រៅនោះ សមស្របនឹងកូនមាន់ដែរឬទេ។ កសិករអាចអង្កេត ស្ថានភាពកូនមាន់ដូចខាងក្រោម៖

- ប្រសិនបើកូនមាន់ត្បុលចូលគ្នាជាក្រុម នោះមានន័យថា អាកាសធាតុត្រជាក់ពេក សម្រាប់កូនមាន់។
- ប្រសិនបើកូនមាន់នៅរាយប៉ាយក្នុងទ្រុងតូច និង ដើរជាធម្មតាទេ នោះមានន័យថា អាកាសធាតុសមស្របនឹងកូនមាន់ត្រូវការ ប៉ុន្តែបើកូនមាន់នៅរាយប៉ាយ និង ដើរចុះដើរឡើង នោះមានន័យថា អាកាសធាតុក្តៅពេកហើយ។

កសិករត្រូវគ្របទ្រុងកូនមាន់ជាប្រចាំ ដើម្បីផ្តល់ភាពកក់ក្តៅដល់កូនមាន់ លើកលែងតែនៅពេលព្រឹក ដែលទាមទារឲ្យកូនមាន់ត្រូវកំដៅ។ នៅពេលយប់ អាកាសធាតុចាប់ផ្តើមចុះត្រជាក់ ដូច្នេះត្រូវប្រើប្រអប់ក្រដាសដើម្បីឲ្យមាន់ចូលដេក និងមានកំដៅនៅពេលយប់។



អាកាសធាតុត្រជាក់ពេក



អាកាសធាតុសមស្រប



អាកាសធាតុក្តៅពេក



ទ្រុងមានព័ទ្ធ សម្រាប់ការពារខ្យល់



ប្រអប់ក្រដាសសម្រាប់កូនមាន់ចូលដេកពេលយប់



បើកគំរបអោយកូនមាន់ត្រូវកំដៅ

## ៥.៤ ការថែទាំមាន់មេបា

សម្រាប់មាន់មេបា កសិករគួរៈ

- មើលជាប្រចាំ ថាតើមេមាន់ផ្តល់ឱកាសដល់មាន់បាជាន់(ពាក់គ្នា)ដែរឬទេ
- ផ្លាស់ប្តូរមេមាន់ ឬគក ប្រសិនបើគកមិនពាក់មេ ឬ មេមិនផ្តល់ឱកាសដល់បា
- រៀបចំសំបុកមាន់ឲ្យបានគ្រប់ចំនួនមេ
- ធ្វើការប្រុងប្រយ័ត្នជាមួយមាន់មេ ពេលខ្លះវាអាចចឹកពង ឬ ក្រាបពងមាន់ដទៃ
- ផ្តល់ចំណីជីវជាតិគ្រប់គ្រាន់ ជាពិសេសពពួកចំណីជាតិរ៉ែ សម្រាប់មាន់មេបា

## ៥.៥ ការរៀបចំកន្លែងសមស្របសម្រាប់មាន់ក្រាបពង

ពេលមេមាន់ផ្តល់ពង (ពី ៨ ទៅ ១០ពង ជាមធ្យម) កសិករត្រូវរៀបចំកន្លែងក្រាបសមស្របៈ

- គួរដាក់ស្លឹកស្តៅ ឬ ក្រូចសើចពីក្រោមពង ដើម្បីការពារសត្វល្អិតចង្រៃ ដូចជាស្រមើល ជាដើម។
- នៅរដូវត្រជាក់ គួររៀបចំចំណី និងទឹកឲ្យមានជាប្រចាំ និងនៅជិតៗ មេមាន់កំពុងក្រាប ធ្វើបែបនេះអាចឲ្យមេមាន់មានពេលវេលាគ្រប់គ្រាន់ដើម្បីក្រាបពង
- នៅរដូវក្តៅ កសិករគួរបាចទឹកជុំវិញទ្រុង ប៉ុន្តែកុំឲ្យប៉ះពងក្នុងសំបុក។ វិធីដ៏ងាយមួយទៀតគឺ គ្រាន់តែដាក់ធុងទឹក ឬ ពាង និង ក្រណាត់សើមជូតពងនៅក្នុងសំបុក។



ដាក់ទឹកពីក្រោម និងក្រណាត់សើម
ដាក់ពីក្រោមសំបុកមាន់ នៅរដូវក្តៅ



ស្លឹកក្រូចសើច ការពារសត្វល្អិតចង្រៃ

## ៥.៦ វិធានការទប់ស្កាត់នៅពេលអាកាសធាតុត្រជាក់ និង ក្តៅ

- **វិធានការទប់ស្កាត់ពេលអាកាសធាតុក្តៅ**

កសិករអាចកាត់បន្ថយអាកាសធាតុត្រជាក់នៅក្នុងទ្រុងតូច ទ្រុងធំ និង ជុំវិញទីធ្លាចិញ្ចឹមតាមវិធានដូចខាងក្រោមៈ

- បាចទឹកក្រោមទ្រុងតូច ទ្រុងធំ និង ជុំវិញទីធ្លាចិញ្ចឹមមាន់
- ដាំពពួកដំណាំបៃតងគ្របពីលើ និង ជុំវិញទីធ្លាចិញ្ចឹមមាន់។
- ដាក់ធុង ឬពាងទឹក និងក្រណាត់សើមនៅពីក្រោមសំបុកមាន់។



បាចទឹកពីក្រោម
និងជុំវិញទីធ្លាចិញ្ចឹមមាន់

- **វិធានការទប់ស្កាត់ពេលអាកាសធាតុត្រជាក់**

នៅពេលអាកាសធាតុត្រជាក់ ការបាំងខ្យល់ជុំវិញទ្រុងតូច និងទ្រុងធំអាចជួយផ្តល់កំដៅដល់មាន់បាន។ ទ្រុងតូច និងធំ អាចបិតបាំងដោយក្រណាត់ ឬសំភារៈដទៃផ្សេងទៀត។

# តារាងកម្មវិធីធ្វើវ៉ាក់សាំង

| អាយុ | | ប្រភេទវ៉ាក់សាំង | ការផ្តល់ចំណី | កន្លែងចិញ្ចឹម |
|---|---|---|---|---|
| ១ ខែ (កូនមាន់) | ១ សប្តាហ៍  | (៣-៥ ថ្ងៃ) ធ្វើវ៉ាក់សាំងជំងឺញូវកាស លើកទី១ | (អាយុតិចជាង ១ខែ) គួរផ្តល់ចំណីសម្រេច ១០០% (មិនចាំបាច់ផ្សំជាមួយចំណីដទៃផ្សេងឡើយ) គួរផ្តល់ចំណីបរិមាណ ២៥ក្រាម សម្រាប់កូនមាន់ ១ក្បាល និង ដាក់ចំណីពី ៣-៤ដង ក្នុង១ថ្ងៃ | មេបណ្តើរយៈពេល ៣ថ្ងៃ |
| | ២ សប្តាហ៍  | (១០-១៥ថ្ងៃ) ធ្វើវ៉ាក់សាំងជំងឺអុតមាន់ | | (អាយុ ៣ ថ្ងៃ - ១ខែ) ចិញ្ចឹមក្នុងទ្រុងតូច |
| | ៣ សប្តាហ៍  | (៣-៤សប្តាហ៍) ធ្វើវ៉ាក់សាំងជំងឺញូវកាស លើកទី២ | | |
| | ៤ សប្តាហ៍  | ពិនិត្យប្រសិទ្ធភាពនៃវ៉ាក់សាំងជំងឺអុតមាន់ក្រោយពីធ្វើបានរយៈពេល៣សប្តាហ៍ | | |
| ២ ខែ (មាន់ជំទង់) |  | (បន្ទាប់ពី ចន្លោះពី ៧ - ១០ សប្តាហ៍) ធ្វើវ៉ាក់សាំងជំងឺអាសន្នរោគ | (អាយុ ១-២ខែ) សមាសភាគផ្សំចំណី៖ ៣០% នៃចំណីសម្រេច ផ្សំជាមួយចំណីមានស្រាប់ ៧០%។ ចំណីបៃតងគួរផ្សំជាមួយតែ ៣០% នៃចំណីផ្សំសរុប។ បរិមាណចំណី៖ ផ្តល់ចំណី ៦០ ក្រាម សម្រាប់មាន់ ១ក្បាល និងផ្តល់ចំនួន ២-៣ដងក្នុងមួយថ្ងៃ។ | (អាយុ ១ខែ ឡើង) ចិញ្ចឹមក្នុងទ្រុង និងទីធ្លាចិញ្ចឹមមានរបងព័ទ្ធជុំវិញ |
| ៣ ខែ (មាន់ធំ) |  | | (អាយុ ២-៤ខែ) សមាសភាគផ្សំចំណី៖ ៣០% នៃចំណីសម្រេច ផ្សំជាមួយចំណីមានស្រាប់ ៧០%។ ចំណីបៃតងគួរផ្សំជាមួយតែ ៣០% នៃចំណីផ្សំសរុប។ បរិមាណចំណី៖ ផ្តល់ចំណី ១២០ ក្រាម សម្រាប់មាន់ ១ក្បាល និងផ្តល់ចំនួន ២-៣ដងក្នុងមួយថ្ងៃ។ | |
| ៤ ខែ (មាន់ធំ) |  | | | |
| ជាទូទៅ កសិករអាចលក់មាន់បាន ចាប់ពីអាយុ ៤ខែឡើង ប៉ុន្តែកសិករត្រូវទុកមាន់មួយចំនួន សម្រាប់ធ្វើមេបា | | | | |
| លើស ៤ខែឡើង (មេបា) |   | (រៀងរាល់ ៦ខែម្តង) ធ្វើវ៉ាក់សាំងជំងឺញូវកាស និង ជំងឺអាសន្នរោគ | (៤ខែ ឡើងទៅ) សមាសភាគផ្សំចំណី៖ ៣០% នៃចំណីសម្រេច ផ្សំជាមួយចំណីមានស្រាប់ ៧០%។ ចំណីបៃតងគួរផ្សំជាមួយតែ ៣០% នៃចំណីផ្សំសរុប។ បរិមាណចំណី៖ ផ្តល់ចំណី ១៥០ ក្រាម សម្រាប់មាន់ ១ក្បាល និងផ្តល់ចំនួន ២-៣ដងក្នុងមួយថ្ងៃ។ | (អាយុ ៤ខែ ឡើង) ចិញ្ចឹមក្នុងទ្រុង និងទីធ្លាចិញ្ចឹមមាន់របងព័ទ្ធជុំវិញ។ (មាន់កំពុងផ្តល់ពង)រៀបចំសំបុក |

សំគាល់៖ ត្រូវប្តូរមេមាន់ រៀងរាល់ ២ឆ្នាំម្តង និងមាន់បា ត្រូវប្តូរចេញ រៀងរាល់ ២.៥ ឆ្នាំម្តង

# ការបង្កើនប្រាក់ចំណេញអតិបរមា

## ១. ពត៌មានទីផ្សារ

កសិករអាចយកមាន់ សម្រាប់ធ្វើជាម្ហូបប្រចាំថ្ងៃ ប៉ុន្តែក៏អាចលក់យកជាលុយបានដែរ។ នៅលើទីផ្សារ មានតម្រូវការសាច់មាន់ខ្ពស់ ជាពិសេសមាន់ពូជក្នុងស្រុក។ ដើម្បីទទួលបានប្រាក់ចំណេញជាអតិបរមា កសិករគួរប្រមូលព័តមានតម្លៃទីផ្សារសាច់មាន់ តាមប្រភពខុសៗគ្នា ដើម្បីធ្វើការប្រៀបធៀបតម្លៃ រួចហើយកសិករអាចសម្រេចចិត្តលក់មាន់ក្នុងតម្លៃណាមួយខ្ពស់ជាងគេ។



កសិករពិភាក្សាជាមួយឈ្មួញអំពីតម្លៃទីផ្សារសាច់មាន់

## ២. ការវិភាគស្ថានភាពអាជីវកម្មចិញ្ចឹមមាន់

កសិករ គួរកត់ត្រាចំណូលចំណាយនៃការចិញ្ចឹមមាន់ ដើម្បីដឹងពីស្ថានភាពអាជីវកម្មរបស់ខ្លួន។ ប្រសិនបើវិភាគឃើញថា មិនទទួលបានប្រាក់ចំណេញទេ កសិករអាចមានលទ្ធភាពស្វែងយល់ពីហេតុផល ចេញពីសៀវភៅកត់ត្រាចំណូលចំណាយបានដោយងាយ។ ឧទាហរណ៍ កសិករអាចពិនិត្យលើសៀវភៅកត់ត្រាចំណូលចំណាយ ថាតើការទិញចំណីសម្រេច វាសមស្របដែរឬទេ។ ប្រសិនបើរកឃើញថា ការចំណាយលើការទិញចំណីសម្រេចខ្ពស់ពេក កសិករត្រូវស្វែងរកចំណីដែលមានស្រាប់ ធ្វើចំណីត្រីផ្អាប់ ចិញ្ចឹមជន្លេនសម្រាប់មាន់ ជាដើម ដើម្បីកាត់បន្ថយការចំណាយលើការទិញចំណីសម្រេចលើទីផ្សារ។



គំរូនៃសៀវភៅកំណត់ត្រាចំណូលចំណាយ

## ៣. ការរៀបចំយុទ្ធសាស្ត្រចិញ្ចឹមមាន់តាមរដូវកាល

ស្ថានភាពអាជីវកម្មចិញ្ចឹមមាន់មានលក្ខណៈខុសគ្នាទៅតាមរដូវកាល ទីកន្លែង និងគ្រួសារនិមួយៗ។ កសិករត្រូវធ្វើការវិភាគអំពីស្ថានភាពនេះ ព្រមទាំងបង្កើតយុទ្ធសាស្ត្រទៅតាមរដូវកាលនិមួយៗ លើការចិញ្ចឹមមាន់។ ស្ថានភាពមួយប្រភេទនៃអាជីវកម្មចិញ្ចឹមមាន់ ត្រូវបានសង្ខេបដូចខាងក្រោម៖

**គំរូនៃយុទ្ធសាស្ត្រចិញ្ចឹមមាន់តាមរដូវកាល**

| រដូវប្រាំង | រដូវវស្សា |
|---|---|
| <u>ស្ថានភាព</u><br>- បរិមាណតម្រូវការសាច់មាន់ខ្ពស់ (មានកម្មវិធីច្រើន)<br>- បរិមាណផ្គត់ផ្គង់សាច់មាន់ទាប (អត្រាមាន់ងាយងាប់ ប្រសិនបើកសិករមិនអនុវត្តបច្ចេកទេស)<br>- តម្លៃសាច់មាន់ខ្ពស់<br>- ពិបាករកចំណីក្នុងស្រុក<br>- ខ្វះកម្លាំងពលកម្មគ្រួសារ (កសិករភាគច្រើនចាកចេញពីភូមិទៅរកការងារធ្វើខាងក្រៅ) | <u>ស្ថានភាព</u><br>- បរិមាណតម្រូវការសាច់មាន់ទាប (មានពិធីតិច)<br>- បរិមាណផ្គត់ផ្គង់សាច់មាន់ខ្ពស់ (ងាយស្រួលចិញ្ចឹម)<br>- តម្លៃសាច់មាន់ធ្លាក់ចុះ<br>- ងាយស្រួលរកចំណីក្នុងស្រុក<br>- កម្លាំងពលកម្មគ្រួសារខ្ពស់ (កសិករភាគច្រើននៅផ្ទះដើម្បីប្រកបការងារស្រែចំការ) |
| <u>យុទ្ធសាស្ត្រ</u> | <u>យុទ្ធសាស្ត្រ</u> |

| | |
|---|---|
| - ផ្តល់ចំណីគុណភាពល្អ ដើម្បីរក្សាឲ្យមាន់មានសុខភាពល្អ<br>- ព្យាយាមចិញ្ចឹមមាន់អោយច្រើន តាមដែលអាចធ្វើទៅបាន | - ផ្តល់ចំណីដែលអាចរកបានក្នុងភូមិ ដើម្បីកាត់បន្ថយការចំណាយលើការទិញចំណី<br>- ព្យាយាមរក្សាចំនួនមាន់ ដើម្បីរក្សាប្រាក់ចំណូលទៀងទាត់<br>- បង្កើនចំនួនមាន់បន្ថែម ប្រសិនបើកសិករអាចប្រើប្រាស់ចំណីរកបាននៅក្នុងភូមិ |

## ៤. ការសន្សំប្រាក់

កសិករអាចកាត់បន្ថយមាន់ងាប់ ដោយអនុវត្តបច្ចេកទេសចិញ្ចឹមមាន់ដែលណែនាំនៅក្នុងសៀវភៅបច្ចេកទេសចិញ្ចឹមមាន់។ តែទោះបីជាយ៉ាងណា មានហេតុផលជាច្រើន ដែលបណ្តាលអោយមាន់ងាប់ ក្នុងនោះហេតុផលខ្លះមិនអាចទប់ស្កាត់បានឡើយ។ នេះមានន័យថា មាន់អាចងាប់ដោយ យថាហេតុណាមួយបាន។ អំឡុងកសិករទទួលចំណូលពីការចិញ្ចឹមមាន់ កសិករត្រូវធ្វើការសន្សំប្រាក់មួយចំណែកណាមួយ ដែលចំណេញ ដើម្បីអាចចាប់ផ្តើមចិញ្ចឹមមាន់ឡើងវិញ ក្នុងករណីមានងាប់។

# បទពិសោធន៍ នៃគម្រោងបញ្ជ្រាបយេនឌ័រ
# ដំណាក់កាលទី២

## ១. សេចក្តីសង្ខេបស្តីពីគម្រោង

- **លក្ខណៈទូទៅ**

  គម្រោងបញ្ជ្រាបយេនឌ័រ ដំណាក់កាលទី២ (PGM2) គឺជាគម្រោងមួយ មានគោលបំណងបញ្ជ្រាបទស្សនៈយេនឌ័រ នៅប្រទេសកម្ពុជា ដែលអនុវត្តដោយក្រសួងកិច្ចការនារី និង ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសជប៉ុន (JICA) ។ គម្រោងនេះ បានចាប់ផ្តើមឡើងចាប់តាំងពី ខែ កញ្ញា ឆ្នាំ ២០១០ និង បញ្ចប់នៅខែ កញ្ញា ឆ្នាំ ២០១៥។

- **គម្រោងសាកល្បងនៅខេត្តកំពង់ចាម**

  គម្រោងបញ្ជ្រាបយេនឌ័រ បានកំណត់យកខេត្តកំពង់ចាម ដើម្បីអនុវត្តគម្រោងសាកល្បង។ គោលបំណងនៃគម្រោងសាកល្បងនេះ គឺដើម្បីលើកកំពស់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីតាមរយៈការចិញ្ចឹមមាន់។ តំបន់គោលដៅរួមមាន៖

  - ជំហានទី ១ និង ២ នៅឃុំស្វាយសែន និង ឃុំតុងរ៉ុង ស្រុកព្រៃឈរ
  - ជំហានទី ៣ និង ៤ នៅឃុំទួលសុភី និង ឃុំមៀន ស្រុកអូររាំងឪ
  - ជំហានទី ៥ និង ៦ នៅឃុំស្វាយទាប និង ឃុំជយោ ស្រុកចំការលើ

- **លទ្ធផលសម្រេចបាន របស់គម្រោងសាកល្បង**

  លទ្ធផលបានបង្ហាញថា ការអនុវត្តតាមបច្ចេកទេសចិញ្ចឹមមាន់ ដែលបានណែនាំ កសិករអាចបង្កើនផលិតកម្មរបស់ខ្លួន និង ទទួលបានប្រាក់ចំណូលបន្ថែមតាមរយៈការលក់មាន់។ ប្រាក់ចំណូលបន្ថែមកសិករបាននាំមកនូវ ផលប៉ះពាល់ជាវិជ្ជមានដល់ជីវភាពរស់នៅរបស់កសិករ។ កសិករដែលទទួលបានជោគជ័យក្នុងគម្រោងបានប្រាប់ថា ទំនាក់ទំនងក្នុងគ្រួសាររបស់គាត់មានភាពប្រសើរជាមុន ព្រមទាំងជម្លោះក្នុងគ្រួសារក៏បានកាត់បន្ថយផងដែរ។

- **សៀវភៅណែនាំបច្ចេកទេស ស្តីពីចិញ្ចឹមមាន់លក្ខណៈគ្រួសារ**

  សៀវភៅណែនាំបច្ចេកទេសនេះ ត្រូវបានរៀបចំឡើង ដោយផ្អែកលើបទពិសោធន៍ជោគជ័យ របស់គម្រោងសាកល្បង ដែលនេះផ្ទុយពីទ្រឹស្តីនៅក្នុងសៀវភៅនានា។ កសិករអាចជឿជាក់បានលើបច្ចេកទេស និង អនុវត្តឲ្យបានច្រើនតាមដែលអាចធ្វើទៅបាន។



លោកជំទាវ វេជ្ជបណ្ឌិត **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ធ្វើទស្សនកិច្ច កសិករចិញ្ចឹមមាន់ នៅស្រុកព្រៃឈរ



លោកជំទាវ **ខុង ស៊ុន អេង** អភិបាលរងខេត្តកំពង់ចាម លើកទឹកចិត្តកសិករអោយទទួលយកជំនាញបច្ចេកទេស ចិញ្ចឹមមាន់តាមរយៈការចូលរួមវគ្គបណ្តុះបណ្តាល



កសិករកំពុងអនុវត្តធ្វើវ៉ាក់សាំងបង្ការជំងឺមាន់



កសិករដែលជោគជ័យកំពុងផ្តល់ចំណីដល់មាន់

## ២. ការណែនាំកសិករឲ្យអភិវឌ្ឍចិញ្ចឹមមាន់ជាជំហានៗ

កសិករ ត្រូវបានលើកទឹកចិត្តឲ្យចិញ្ចឹមមាន់ដោយអនុវត្តតាមបច្ចេកទេស ដូចបរិយាយក្នុងសៀវភៅណែនាំ។ ទោះបីជាយ៉ាងណា វាមានភាពលំបាកសម្រាប់កសិករក្នុងការអនុវត្តបច្ចេកទេសក្នុងពេលតែមួយ ជាពិសេសសម្ភារៈសម្រាប់ចិញ្ចឹមមាន់ ។ ខាងក្រោមនេះ ជាគំរូជោគជ័យមួយ ដែលបង្ហាញអំពីដំណើរការជាជំហានៗ ក្នុងការអភិវឌ្ឍន៍ដ៏ជោគជ័យរបស់កសិករក្រុមគោលដៅរបស់គម្រោងបញ្ញាបយេនឌ័រ PGM2 ដូចខាងក្រោម៖

(១)



ចិញ្ចឹមមាន់ (រួមទាំងមាន់ធំ) ក្នុងទ្រុងតូច

(២)



ចាប់ផ្តើមសង់ទ្រុងធំ សម្រាប់ចិញ្ចឹមមាន់

(៣)



ទ្រុងមាន់ធំ កំពុងសង់ សម្រាប់ចិញ្ចឹមមាន់

(៤)



ទ្រុងមាន់ធំសង់រួច តែមិនទាន់មានរបងព័ទ្ធជុំវិញ

(៥)



ចិញ្ចឹមមាន់ក្នុងទ្រុងធំ ដែលគ្មានរបងព័ទ្ធជុំវិញទីធ្លា

(៦)



ត្រូវចិញ្ចឹមកូនមាន់ក្នុងទ្រុងតូចជាប្រចាំ

(៧)



ទីធ្លាមានរបងព័ទ្ធជុំវិញ ត្រូវបានសង់រួចរាល់

(៨)



ដំណាំទ្រើងគ្របពីលើទីធ្លា សម្រាប់ជាម្លប់

# បទពិសោធន៍ជោគជ័យ នៃក្រុមគោលដៅ
# គម្រោងបញ្ញាបយេនឌ័រ ដំណាក់កាលទី២ (PGM2)

## ១. ករណី "ការបង្កើនប្រាក់ចំណូលតាមរយៈសកម្មភាពចិញ្ចឹមមាន់"



អ្នកមីង **នន់ ផាត** មានអាយុ ៥២ឆ្នាំ ជាស្ត្រីមេម៉ាយរស់នៅភូមិស្ទឹង ឃុំទួលសុភី ស្រុកអូររាំងឪ ខេត្តកំពង់ចាម។ គាត់រៀនបានត្រឹមថ្នាក់ទី១ចាស់។ ស្វាមីរបស់គាត់បានស្លាប់ នៅក្នុងឆ្នាំ១៩៩២ ដោយសារជម្ងឺធ្ងន់ធ្ងរមិនអាចព្យាលបាន។ ចាប់តាំងពីពេលនោះមក គាត់បានធ្វើស្រែ លក់ចាប់ហួយបន្តិចបន្តួចនៅផ្ទះ និងចិញ្ចឹមមាន់ដើម្បីរកប្រាក់ចំណូល។ អ្នកមីង មានកូនស្រី ៤នាក់ និងកូនប្រុស ១នាក់។ ក្នុងចំណោមកូនស្រីទាំង ៤របស់គាត់ មានកូនស្រី ២នាក់ទៅធ្វើការរោងចក្រកាត់ដេរនៅភ្នំពេញ។ គាត់បានទទួលព័ត៌មានអំពីគម្រោងបញ្ញាបយេនឌ័រដំណាក់កាលទី២ តាមរយៈការផ្សព្វផ្សាយរបស់មេភូមិ។ បន្ទាប់មកកសិករចូលរួមចុះទស្សនកិច្ចសិក្សានៅស្រុកព្រៃឈរ ដែលរៀបចំដោយគម្រោងបញ្ញាបយេនឌ័រដំណាក់កាលទី២ នៅខែ ធ្នូ ឆ្នាំ ២០១២។ គាត់ចាប់អារម្មណ៍ លើការចិញ្ចឹមមាន់ដោយប្រើប្រាស់បច្ចេកទេសសមស្រប ដើម្បីរកប្រាក់ចំណូល និង សម្រេចចិត្តចូលរួមជាមួយសកម្មភាពបណ្តុះបណ្តាលរបស់គម្រោងបញ្ញាបយេនឌ័រ ដំណាក់កាលទី២។ តាំងពីស្វាមីគាត់បានស្លាប់ គាត់បានចិញ្ចឹមមាន់តាមទំលាប់ តែមាន់តែងងាប់ និង បាត់ស្ទើរអស់។ ហេតុដូចនេះគាត់មិនបានទទួលប្រាក់ចំណេញពីសកម្មភាពចិញ្ចឹមមាន់ទេ។



តាំងពីចាប់ផ្តើមចូលរួមវគ្គបណ្តុះបណ្តាលមក គាត់បានចាប់ផ្តើមចិញ្ចឹមមាន់ដោយប្រើបច្ចេកទេសដែលទទួលបានតាមរយៈគម្រោង។ ជាលទ្ធផល ចំនួនមាន់របស់គាត់មានការកើនឡើងជាលំដាប់ ដោយសារការថែទាំល្អ ធ្វើវ៉ាក់សាំងបានត្រឹមត្រូវ និងផ្តល់ចំណីជីវជាតិគ្រប់គ្រាន់។ ដោយហេតុថា គាត់ចិញ្ចឹមដាក់ក្នុងទ្រុងធំ និងទ្រុងតូច ទើបមាន់គាត់មិនបាត់ដូចមុនឡើយ។ ក្នុងកំឡុងពេល ៣ ទៅ ៤ខែ គាត់អាចលក់មាន់បាន ២ ទៅ ៣ដង ហើយគាត់លក់ម្តងចន្លោះពី ១០គ.គ ទៅ១៥គ.ក ១គីឡូក្រាមក្នុងតម្លៃប្រមាណ ១៤០០០រៀល។ ជាងនេះទៀត គាត់លក់មាន់បានចំណូលប្រមាណ ៦៥៧,៦០០រៀល អំឡុងពេលសែនក្បាលទឹក។



គាត់គិតថា កត្តាដែលធ្វើឲ្យការចិញ្ចឹមមាន់តាមលក្ខណៈបច្ចេកទេសទទួលបានជោគជ័យគឺ ដោយសារគាត់មានឆន្ទៈខ្ពស់ក្នុងការចិញ្ចឹម មានការលើកទឹកចិត្ត និងគាំទ្រពីសមាជិកគ្រួសារ ក្នុងសកម្មភាពចិញ្ចឹមមាន់ និងមានទំនុកចិត្តក្នុងការអនុវត្តចំណេះដឹង ព្រមទាំងបច្ចេកទេសផ្សេងៗដែលបានរៀន។ គាត់បានបន្ថែមថា ប្រាក់ចំណូលបន្ថែមទទួលបានតាមរយៈការចិញ្ចឹមមាន់ គឺបានរួមចំណែកខ្លាំងក្នុងការដោះស្រាយជីវភាពប្រចាំថ្ងៃរបស់គាត់ដូចជា ទិញម្ហូបអាហារ ទិញជីដាក់ស្រែ និងថ្នាំបាញ់ស្រូវ បុណ្យទានផ្សេងៗ និងថែទាំសុខភាពរបស់គាត់។ បន្ទាប់ពីចូលរួមវគ្គបណ្តុះបណ្តាល ដែលផ្តល់ដោយគម្រោងបញ្ញាបយេនឌ័រដំណាក់កាលទី២ គាត់មានអារម្មណ៍ថាគាត់មានភាពក្លាហានជាងមុនព្រមទាំងមានទំនុកចិត្តក្នុងការអនុវត្តចំណេះដឹង និងបច្ចេកទេស។ សព្វថ្ងៃនេះគាត់ចេះពីរបៀបកត់ត្រាចំណូលចំណាយ ហេតុដូចនេះជីវភាពគ្រួសាររបស់គាត់មានភាពប្រសើរជាងមុន។ លើសពីនេះទៀត គាត់បានចែករំលែកព័ត៌មាន និងណែនាំពីបច្ចេកទេសចិញ្ចឹមមាន់ដល់អ្នកជិតខាងដែលមិនបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលផងដែរ។

ទោះបីជាគាត់មានការបារម្មណ៍ពីបញ្ហាចោរលួចមាន់យ៉ាងណា ក៏អ្នកមីង នន់ ផាត មិនបារម្មណ៍អំពីបញ្ហាជីវភាពប្រចាំថ្ងៃរបស់គាត់ដូចពីមុនទេ ដោយសារគាត់អាចលក់មាន់ដើម្បីដោះស្រាយបញ្ហាបន្ទាន់បាន។ គាត់និងកូនស្រីគាត់មានបំណងចង់ពង្រីកការចិញ្ចឹមមាន់នេះ បន្ថែមទៀតនាពេលអនាគត ដោយប្រើប្រាស់ប្រាក់ចំណូលពីសកម្មភាពចិញ្ចឹមមាន់៕

## ២. ករណី "ការចិញ្ចឹមមាន់ពិតជាបានជួយឲ្យជីវភាពមានភាពប្រសើរឡើង"



បងស្រី **អ៊ី ឡៃហ៊ិន** អាយុ៣០ឆ្នាំ ជាកសិករស់នៅភូមិតុងរ៉ុង ឃុំតុងរ៉ុង ស្រុកព្រៃឈរ ខេត្តកំពង់ចាម ដែលជាភូមិគោលដៅរបស់គម្រោងសាកល្បងបញ្ច្រាបយេនឌ័រ ដំណាក់កាលទី២(PGM2) បានផ្ដល់ឱកាសឲ្យស្ត្រី និង បុរសចូលរួមរៀនពីបច្ចេកទេសចិញ្ចឹមមាន់ ដើម្បីជួយបង្កើនជីវភាពរបស់ពួកគាត់។ បងស្រីមានកូនស្រី ២នាក់រស់នៅក្នុងបន្ទុក។ គាត់មានដីស្រែប្រហែល ១ហិចតា និង មានទីធ្លាជុំវិញផ្ទះល្មមអាចចិញ្ចឹមគោ និងមាន់ ហើយមុខរបរចំបងនៅក្នុងគ្រួសាររបស់គាត់ គឺធ្វើស្រែ។



កន្លងមក បងស្រីធ្លាប់ចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារដែរ ប៉ុន្តែមិនសូវបានផលទេ ព្រោះមាន់ចេះតែឈឺ និងងាប់។ ប្ដីរបស់បងស្រីបានចូលរួមវគ្គបណ្ដុះបណ្ដាលជុំទី១ ហើយបានចែករំលែកចំណេះដឹងដល់គាត់ដែរ។ ប្ដីរបស់គាត់រវល់លក់ការេមកី និងធ្វើស្រែ ដូច្នេះគាត់បានលើកទឹកចិត្តបងស្រីឲ្យចូលរួមក្នុងវគ្គបណ្ដុះបណ្ដាលបច្ចេកទេសចិញ្ចឹមមាន់ជុំទីពីរ ហើយបងស្រីក៏សម្រេចចិត្តចូលរួម ព្រោះគាត់ក៏ចង់បានចំណេះដឹងដោយខ្លួនឯង ដែរ។ បន្ទាប់ពីបានចូលរួមវគ្គបណ្ដុះបណ្ដាលរួចមក គាត់បានរៀនបច្ចេកទេស មួយចំនួនដូចជា ការសង់ទ្រុង ចិញ្ចឹមជន្លេន ការថែទាំ ការធ្វើវ៉ាក់សាំង និងរបៀបផ្សំចំណីជាដើម។ បន្ទាប់ពីពិភាក្សាជាមួយប្ដី គាត់បានសម្រេចចិត្តចិញ្ចឹមមាន់តាមលក្ខណៈបច្ចេកទេសវិញ។ ប្ដីរបស់គាត់ជួយធ្វើទ្រុង ឯគាត់ជាអ្នកថែទាំមាន់ ផ្សំចំណីមាន់ ធ្វើវ៉ាក់សាំងអោយកូនមាន់ និងសំអាតទ្រុងមាន់ជាដើម។ ទោះបីប្ដីរបស់គាត់រវល់ការងារយ៉ាងណាក៏ដោយ ក៏គាត់នៅតែជួយមើលថែកូន និងដាំស្ល។



បន្ទាប់ពីបានអនុវត្តបច្ចេកទេសចិញ្ចឹមមាន់ រយៈពេល៥ខែរួចមក គាត់លក់មាន់បានបីដងឲ្យទៅឈ្មួញនៅក្នុងភូមិ ដែលលើកទី១លក់បាន២០គីឡូក្រាម លើកទី២លក់បាន១០គីឡូក្រាម និងលើកទី៣លក់បាន៥គីឡូក្រាម (១គីឡូក្រាមលក់បានពី ១៣ ០០០រៀល ទៅ ១៤ ០០០រៀល នៅរដូវវស្សា)។ ការចិញ្ចឹមមាន់តាមលក្ខណៈបច្ចេកទេសនេះ បងស្រីបានជួបប្រទះបញ្ហាដូចជា មានមាន់ងាប់តិចតួច (ក្នុងមាន់១០ក្បាល មានមាន់មួយក្បាលងាប់) និងតម្លៃវ៉ាក់សាំងចេះតែឡើងថ្លៃជាដើម។ បងតែងតែចែករំលែកបទពិសោធន៍របស់គាត់ដល់អ្នកជិតខាងអំពីការធ្វើវ៉ាក់សាំង ការថែទាំ និងការផ្សំចំណីមាន់ជាដើម។ បងស្រីបានធ្វើការកត់ត្រារាល់ការចំណាយ និងចំណូលពីការចិញ្ចឹមមាន់។ គាត់ជាអ្នកគ្រប់គ្រងរាល់ការចំណាយផ្សេងៗដូចជា ការទិញរបស់របរសំរាប់ប្រើប្រាស់ ទិញសៀវភៅសម្រាប់កូនរៀន ទិញថ្នាំពេលកូនឈឺជាដើម ប៉ុន្តែគាត់ក៏បានពិភាក្សាជាមួយប្ដី ពេលត្រូវការដោះស្រាយបញ្ហាធំៗ និងលក់មាន់ដើម្បីបំពេញតម្រូវការរបស់ពួកគាត់។

នៅថ្ងៃខាងមុខបងស្រីមានបំណងចង់ពង្រីកការចិញ្ចឹមមាន់បន្ថែម ព្រោះគាត់គិតថាចំណូលពីការចិញ្ចឹមមាន់អាចជួយផ្គត់ផ្គង់ឲ្យកូនបានរៀនចប់វិទ្យាល័យ ឬបន្តទៅមហាវិទ្យាល័យទៀត។ គាត់មានការសប្បាយរីករាយរកអ្វីនឹងមកប្រៀបផ្ទឹមពុំបានទេ ដោយសារចំណូលពីការចិញ្ចឹមមាន់ បានចូលរួមចំណែកជួយកាត់បន្ថយការខ្វះខាតប្រចាំថ្ងៃ និងបង្កើនជីវភាពក្នុងគ្រួសារ ព្រមទាំងធ្វើឲ្យគ្រួសាររបស់គាត់មានសុភមង្គល៕

## ៣. ករណី "ការចូលរួមគាំទ្រពីសមាជិកគ្រួសារជាបុរស ក្នុងសកម្មភាពចិញ្ចឹមមាន់"



បងប្រុស **ប៉ាន ហ៊ុន** អាយុ ៣៦ឆ្នាំ ជាកសិកររស់នៅក្នុងភូមិស្ទឹង ឃុំទួលសុភី ស្រុកអូរាំងឪ ខេត្តកំពង់ចាម មានប្រពន្ធ ឈ្មោះ ហ៊ាន វណ្ណា អាយុ ៣០ឆ្នាំ និងមានកូន ២នាក់នៅក្នុងបន្ទុក ស្រី១នាក់ និងប្រុស១នាក់។ គាត់ប្រកបរបរធ្វើស្រែ លក់កំលាំងពលកម្ម និងចិញ្ចឹមមាន់។

ប្រពន្ធរបស់គាត់ បានចូលរួមទស្សនកិច្ចសិក្សានៅស្រុកព្រៃឈរ ដែលរៀបចំដោយគម្រោងបញ្ច្រាបយេនឌ័រ ដំណាក់កាលទី២ ក្នុងខែធ្នូ ឆ្នាំ២០១២ និងចែករំលែកព័ត៌មាននៃការចូលរួមធ្វើទស្សនកិច្ចសិក្សា នៅស្រុកព្រៃឈរ អំពីបច្ចេកទេសចិញ្ចឹមមាន់ជាមួយគាត់។ ប្រពន្ធគាត់បានពិភាក្សាជាមួយគាត់ អំពីការចូលរួមវគ្គបណ្តុះបណ្តាលជាមួយគម្រោងបញ្ច្រាបយេនឌ័រ ដំណាក់កាលទី២ ហើយគាត់ក៏បានសម្រេចចិត្តអោយប្រពន្ធចូលរួមក្នុងសកម្មភាពគម្រោង បន្ទាប់ពីពិភាក្សាគ្នា ប្រពន្ធគាត់បានចូលរួមរៀនអំពីចំណេះដឹង និងបច្ចេកទេសចិញ្ចឹមមាន់ និងបានផ្លាស់ប្តូរពីការចិញ្ចឹមតាមប្រពៃណីមកតាមបច្ចេកទេសវិញ។ គាត់ពុំបានចូលរៀនក្នុងវគ្គបណ្តុះបណ្តាលទេដោយសារ គាត់រវល់ធ្វើស្រែ និងលក់កំលាំងពលកម្ម ប៉ុន្តែគាត់បានជំរុញលើកទឹកចិត្តអោយប្រពន្ធគាត់ចូលរួមក្នុងវគ្គបណ្តុះបណ្តាល និងអនុវត្តបច្ចេកទេសទាំងនោះយ៉ាងសកម្មបំផុត ព្រោះគាត់យល់ឃើញថាការចិញ្ចឹមមាន់នេះមានផលប្រយោជន៍សម្រាប់គ្រួសារគាត់ ប្រសិនបើពួកគាត់អនុវត្តតាមចំណេះដឹង និងបច្ចេកទេសបានត្រឹមត្រូវ។



ប្រពន្ធរបស់គាត់តែងតែ ចែករំលែកចំណេះដឹងដែលទទួលបានពីវគ្គ បណ្តុះបណ្តាលដល់គាត់។ តាមរយៈការចែករំលែកចំណេះដឹង និងការខិតខំប្រឹងប្រែងរបស់ប្រពន្ធគាត់ ធ្វើឲ្យគាត់បានចូលរួមជួយក្នុងសកម្មភាពចិញ្ចឹមមាន់តាមបច្ចេកទេស ដូចជា ជួយធ្វើទ្រុងធំ/តូច បន្តក់រឺចាក់វ៉ាក់សាំង និងផ្តល់ចំណីមាន់ជាដើម។ មិនតែប៉ុណ្ណោះគាត់បានជួយការងារផ្ទះ ដូចជា ដាំបាយ ដងទឹក បោកខោអាវ បោសសំអាតផ្ទះជាដើមដោយមិនប្រកាន់ការងារស្ត្រី រឺបុរសឡើយ ព្រោះគាត់យល់ថា បើប្រពន្ធគាត់មិននៅផ្ទះ គាត់ក៏អាចធ្វើបានដែរ។ ពីមុនគាត់កំរជួយ ធ្វើការងារផ្ទះប្រពន្ធគាត់ណាស់ ហើយក៏មិនបានខ្វល់ពីអ្វីដែលប្រពន្ធគាត់ធ្វើដែរ។ អាកប្បកិរិយា និងគំនិតរបស់គាត់បានផ្លាស់ប្តូរបន្ទាប់ពីប្រពន្ធរបស់គាត់បានចូលរួមវគ្គបណ្តុះបណ្តាល។



តាមរយៈការប្រើប្រាស់ចំណេះដឹង និងបច្ចេកទេសចិញ្ចឹមមាន់ គ្រួសាររបស់គាត់ទទួលបានប្រាក់ចំណូលច្រើនជាងមុន។ គាត់ និងប្រពន្ធរបស់គាត់ លក់មាន់បាន ៤ដង តាំងពីខែ កញ្ញា ឆ្នាំ ២០១៣ រហូតដល់ពេលនេះ ហើយក្នុង ១ដង គាត់លក់បានពី ១២០.០០០រៀល ទៅ ១៧០.០០០រៀល។ គាត់តែងតែពិភាក្សាជាមួយប្រពន្ធគាត់ ពីការប្រើប្រាស់ប្រាក់ចំណូលទាំងនោះ ដូចជាអោយកូនរៀន ថែទាំសុខភាព ទិញអាហារប្រចាំថ្ងៃ ទិញចំណីមាន់ និងវ៉ាក់សាំងជាដើម។ គាត់គិតថា ប្រពន្ធរបស់គាត់មានទំនុកចិត្តលើខ្លួនឯងក្នុងការប្រើប្រាស់ចំណេះដឹង និងបច្ចេកទេសចិញ្ចឹមមាន់ ព្រមទាំង ង្កើនទំនាក់ទំនងល្អជាមួយអ្នកជិតខាង។ ឧទាហរណ៍ ប្រពន្ធគាត់អាចសួរ អ្នកជិតខាង អំពីព័ត៌មានថ្លៃមាន់ និងចេះនាំគ្នាប្រមូលមាន់យកទៅលក់នៅឯផ្សារនៅពេលឈ្មួញបង្អាប់មាន់គាត់ ព្រមទាំងចរចាជាមួយអាជីវករ ដើម្បីទទួលបានតម្លៃថ្លៃ។ ប្រពន្ធគាត់ហ៊ានតេ ទៅសួរគ្រូបណ្តុះបណ្តាល នៅពេលមាន់គាត់ឈឺ។ គាត់យល់ឃើញថា ការគាំទ្រពីសមាជិកគ្រួសារពិសេសប្តី ជាកត្តាដែលធ្វើអោយស្ត្រី ទទួលបានជោគជ័យក្នុងការចិញ្ចឹមមាន់។ គាត់ក៏បានបន្ថែមទៀតថា ការលើកទឹកចិត្តពីអាជ្ញាធរ ដើម្បីជម្រុញអោយស្ត្រីចូលរួមក្នុងសកម្មភាពសហគមន៍ ពិតជាមានសារៈសំខាន់ណាស់៕

## ៤. ករណី "មុខរបរចិញ្ចឹមមាន់ដែលទទួលបានជោគជ័យ"



បងស្រី **ហ៊ុល សុទ្ធី** មានអាយុ ៤៥ឆ្នាំ រៀនបានត្រឹមថ្នាក់ទី៧ចាស់ ជាកសិកររស់នៅភូមិបឹងផ្តិល ឃុំទួលសុភី ស្រុកអូរាំងឪ ខេត្តកំពង់ចាម។ បងស្រី មានកូន០២នាក់ ស្រី ០១នាក់ ប្រុស ០១នាក់ (កំពុងសិក្សា) ប្តីរបស់គាត់ជាគ្រូបង្រៀន។ សព្វថ្ងៃបងស្រីប្រកបមុខរបរដូចជា ជាងកាត់ដេរ ចិញ្ចឹមជ្រូក ចិញ្ចឹមមាន់ និងធ្វើស្រែ។ គាត់មានដីកម្មសិទ្ធចំនួន ៥ហិកតា។ គាត់ទទួលបានព័ត៌មានអំពីគម្រោងបញ្ច្រាបយេនឌ័រដំណាក់កាលទី២ តាមរយៈមេភូមិ ហើយបានចូលរួមវគ្គបណ្តុះបណ្តាលអំពីបច្ចេកទេសចិញ្ចឹមមាន់ ទោះបីជាគាត់មានមុខរបរច្រើន និងមានការមមាញឹកយ៉ាងណាក៏ដោយ។

មុនពេលចូលរួមគម្រោង គាត់បានចិញ្ចឹមមាន់ជាលក្ខណៈប្រពៃណី ដោយគ្មានចំណេះដឹង និងបច្ចេកទេសច្បាស់លាស់។ ដូចច្នេះមាន់របស់គាត់ងាប់ដោយសារជំងឺ ឡាន/ម៉ូតូកិន និងចោរលួច។ បន្ទាប់ពីគាត់បានរៀនបច្ចេកទេសចិញ្ចឹមមាន់ គាត់បានបែងចែកពេលវេលាច្បាស់លាស់ក្នុងការផ្តល់ចំណី ធ្វើទ្រុងធំ ទ្រុងតូច ធ្វើវ៉ាក់សាំង និងបច្ចេកទេសផ្សេងៗទៀត។ ដោយមានការជំរុញលើកទឹកចិត្ត និងគាំទ្រពីសមាជិកគ្រួសារ ក្នុងសកម្មភាពចិញ្ចឹមមាន់ ធ្វើឲ្យទិន្នផលមាន់មានការកើនឡើងយ៉ាងឆាប់រហ័ស។ គាត់បានលក់មាន់មួយដង បាន១០គីឡូក្រាម (១គីឡូ=១៤,០០០រៀល) និងធ្វើជាម្ហូបអស់ ៤០ក្បាល។ ប្រាក់ចំណូលដែលទទួលបានពីការចិញ្ចឹមមាន់ គាត់បានយកទៅទិញចំណីមាន់ខ្លះ និងទិញម្ហូបអាហារខ្លះ។ គាត់បានលក់មាន់ឲ្យឈ្មួញដែលមកទិញដល់ភូមិ ពីព្រោះតម្លៃមាន់ខុសគ្នាបន្តិចបន្តួចពីតម្លៃមាន់លើទីផ្សារ ហើយគាត់មិនចាំបាច់ចំណាយពេលវេលា និងសោហ៊ុយក្នុងការធ្វើដំណើរទៅផ្សារទេ។ ម្យ៉ាងវិញទៀតគ្រួសារ របស់គាត់មានទំនាក់ទំនងល្អ និង បានចែករំលែកបទពិសោធន៍នៃការចិញ្ចឹមមាន់ជាមួយអ្នកជិតខាងដូចជា របៀបនៃការផ្សំចំណី របៀបបំបែកកូនមាន់ និង ចាក់វ៉ាក់សាំង។



គាត់គិតថាកត្តាដែលធ្វើអោយការចិញ្ចឹមមាន់ទទួលបានជោគជ័យ គឺ មានការលើកទឹកចិត្តពីសមាជិកគ្រួសារ គាំទ្រ និង ជួយចែករំលែកការងារដូចជា ជួយធ្វើទ្រុងធំ ទ្រុងតូច និង ធ្វើវ៉ាក់សាំង។ ម្យ៉ាងវិញទៀតគាត់គិតថាទីធ្លាផ្ទះរបស់គាត់ ក៏ជាកត្តាដែលធ្វើអោយការចិញ្ចឹមមាន់ទទួលបានជោគជ័យ ដោយសារមានទីធ្លាធំទូលាយងាយស្រួលក្នុងការសង់ទ្រុងធំសំរាប់មាន់ ដែលជាចំណុចសំខាន់សំរាប់ការចិញ្ចឹមមាន់។ គាត់យល់ឃើញថា សកម្មភាបចិញ្ចឹមមាន់ជាមុខរបរមួយ ហើយជាសកម្មភាពរកប្រាក់ចំណូលសមរម្យមួយសំរាប់ស្ត្រីដែលធ្វើនៅផ្ទះ ហើយគាត់អាចមានពេលទំនេរច្រើនក្នុងការរកស៊ីមុខរបរផ្សេងៗទៀត។



គាត់មិនមានបញ្ហាក្នុងការអនុវត្តន៍បច្ចេកទេសចិញ្ចឹមមាន់ ដែលគាត់បានចូលរួមជាមួយគម្រោងបញ្ច្រាបយេនឌ័រដំណាក់កាលទី២។ នៅខែកញ្ញា ឆ្នាំ ២០១៣ គាត់មានមាន់ ១០០ និងកូនមាន់ ៦០ (ផ្ទះរបស់គាត់មានទីធ្លាធំទូលាយសំរាប់ការចិញ្ចឹមមាន់)។ គាត់យល់ឃើញថា សកម្មភាពចិញ្ចឹមមាន់បាន ផ្តល់ប្រយោជន៍ដល់គ្រួសារគាត់ព្រោះ មាន់អាចធ្វើជាម្ហូបនៅពេលបងប្អូនរបស់គាត់មកលេង ហើយងាយស្រួលក្នុងការលក់ជាងសត្វដទៃទៀត។ គាត់សប្បាយរីករាយក្នុងការប្រើប្រាស់ចំណេះដឹង និងបច្ចេកទេសចិញ្ចឹមមាន់ ព្រោះគាត់អាចរកប្រាក់ចំណូលបន្ថែមបាន។ គាត់មានបំណងពង្រីកការចិញ្ចឹមមាន់បន្ថែមទៀតនាពេលអនាគត ដើម្បីយកប្រាក់ចំណូលនេះសម្រាប់ផ្គត់ផ្គង់កូនៗរបស់គាត់រៀនបន្តទៀត៕

# សារៈសំខាន់ នៃទំនាក់ទំនងល្អក្នុងគ្រួសារ និង សង្គម ដើម្បីចិញ្ចឹមមាន់ទទួលបានជោគជ័យ

ការចិញ្ចឹមមាន់លក្ខណៈគ្រួសារ ជាមុខរបរសម្រាប់គ្រួសារ ប៉ុន្តែមិនមែនសម្រាប់ក្រុមហ៊ុន ឬ អង្គការនោះទេ។ ដើម្បីទទួលបានលទ្ធផលជោគជ័យ ក្នុងការចិញ្ចឹមមាន់ ទំនាក់ទំនងល្អក្នុងគ្រួសារ និង សង្គម គឺមានសារៈសំខាន់ខ្លាំងណាស់។

## ១. ប្រពន្ធ

ការចិញ្ចឹមមាន់ ជាប្រភពចំណូលមួយដ៏សំខាន់ សម្រាប់ស្ត្រីជាប្រពន្ធ ពីព្រោះ ស្ត្រីអាចចិញ្ចឹមមាន់បានដោយនៅផ្ទះ និង ប្រើបច្ចេកទេសចិញ្ចឹមមាន់ មានលក្ខណៈងាយៗ ដោយគ្រាន់តែស្ត្រីចូលរួមរៀនសូត្របច្ចេកទេសទាំងនោះ។ ស្ត្រីមានទំនុកចិត្តដោយខ្លួនឯង និង ចូលរួមយ៉ាងសកម្មក្នុងការធ្វើសេចក្តីសម្រេចចិត្តនៅក្នុងគ្រួសារ ដោយសារស្ត្រីរួមចំណែករកប្រាក់ចំណូលសម្រាប់គ្រួសារតាមរយៈការចិញ្ចឹមមាន់។ លើសពីនេះ ជំលោះដែលតែងកើតមានញឹកញាប់ក្នុងគ្រួសារដោយសារភាពខ្វះខាតចំណូល ក៏បានថយចុះដោយសារប្រាក់ចំណូលបន្ថែមពីការចិញ្ចឹមមាន់។ ទំនាក់ទំនងល្អរវាងបុរសជាប្តី គឺជាកត្តាជោគជ័យក្នុងការចិញ្ចឹមមាន់។ ប្រសិនបើមានទំនាក់ទំនងល្អរវាងប្តី និង ប្រពន្ធ នោះបុរសនឹងលើកទឹកចិត្តឲ្យស្ត្រីចូលរួមវគ្គបណ្តុះបណ្តាលដើម្បីរៀនជំនាញ ជួយរៀបចំទ្រុងចិញ្ចឹមមាន់ ដែលជាផ្នែកមួយដ៏សំខាន់ក្នុងការចិញ្ចឹមមាន់បានជោគជ័យ ជាងនេះទៅទៀត ការងាររបស់ស្ត្រីនៅក្នុងគ្រួសារក៏បានជួយសម្រាលផងដែរ។

## ២. ប្តី

ការចិញ្ចឹមមាន់ ជាប្រភពចំណូលមួយដ៏សំខាន់ សម្រាប់បុរសជាប្តីផងដែរ។ ការចិញ្ចឹមមាន់អាចធ្វើបានស្របពេលគ្នាជាមួយការងារស្រែចំការដែលជាមុខរបរទី១ សម្រាប់កសិករភាគច្រើន។ មាន់អាចលក់បានក្នុងរយៈពេល ៣ ទៅ ៤ខែ ប្រសិនបើកសិករយកចិត្តទុកដាក់ថែទាំបានល្អ ដូច្នេះកសិករនឹងទទួលបានប្រាក់ចំណូលសម្រាប់បំពេញតំរូវការចាំបាច់នានាបានដោយងាយ។ បុរសជាប្តី ដែលជាអ្នកមេគ្រួសារ និងជាអ្នករកប្រាក់ចំណូលចំបងនោះ ក៏បានធូរស្រាលបន្ទុកមួយចំណែកធំ តាមរយៈចំណូលបន្ថែមពីការចិញ្ចឹមមាន់។ ជាលទ្ធផល ទំនាក់ទំនងល្អក្នុងគ្រួសារជាពិសេសស្ត្រី មានភាពប្រសើរឡើង។ ទំនាក់ទនងល្អនេះហើយ ជាគន្លឹះដ៏ជោគជ័យមួយក្នុងការងារចិញ្ចឹមមាន់ ព្រោះមានករណីជាច្រើន ដែលស្ត្រីដើរតួនាទីសំខាន់ក្នុងសកម្មភាពចិញ្ចឹមមាន់។ ប្រសិនបើមានទំនាក់ទំនងល្អរវាងប្តី និងប្រពន្ធ នោះពួកគាត់នឹងចែករំលែកនូវចំណេះដឹង និង ជំនាញដែលទទួលបានពីវគ្គបណ្តុះបណ្តាលអោយគ្នាទៅវិញទៅមក និងជួយគ្នាទៅវិញទៅមកទាំងក្នុងការងារចិញ្ចឹមមាន់ និងការងារផ្ទះ។

## ៣. កូន

ផ្អែកលើបទពិសោធន៍នៃគម្រោងបញ្ញាបយេនឌ័រដំណាក់កាលទី ២ (PGM2) កសិករបានប្រើប្រាស់ប្រាក់ចំណូលបន្ថែមដែលទទួលបានពីការលក់មាន់ ក្នុងគោលបំណងបញ្ជូនកូនទៅរៀន ព្រមទាំងបញ្ជាក់ទៀតថា ពួកគាត់នឹងចំណាយវាច្រើនថែមទៀត ប្រសិនបើទទួលបានចំណូលកាន់តែច្រើនពីការចិញ្ចឹមមាន់។ ពេលខ្លះ ស្ត្រីជាម្តាយមានការលំបាកក្នុងការអាន និង សរសេរ ដោយសារមិនចេះអក្សរ។ ពេលទំនេរ កូនរបស់គាត់បានអានសម្ភារៈបង្រៀន ដូចជារូបភាពផ្ទាំងបង្ហាញ សៀវភៅណែនាំបច្ចេកទេស និងសៀវភៅកត់ត្រាចំណូលចំណាយអោយម្តាយស្តាប់។

## ៤. ស្ត្រីមេម៉ាយ

ការចិញ្ចឹមមាន់ មិនគ្រាន់តែជាប្រភពចំណូលមួយដ៏សំខាន់មួយ សម្រាប់ប្រពន្ធ និង ប្ដីប៉ុណ្ណោះទេ តែក៏សម្រាប់ស្ត្រីមេម៉ាយផងដែរ។ ស្ត្រីមេម៉ាយអាចចិញ្ចឹមមាន់នៅផ្ទះ ដោយអនុវត្តបច្ចេកទេសដ៏សាមញ្ញ ដែលទទួលបានពីវគ្គបណ្តុះបណ្តាល។ ដំណាក់កាលខ្លះ នៃបច្ចេកទេសចិញ្ចឹមមាន់របស់ PGM2 ដែលទាមទារកម្លាំងពលកម្មខ្លាំង ដូចជាការសង់ទ្រុងជាដើម ប្រហែលជាមានការលំបាកសម្រាប់ស្ត្រីមេម៉ាយ។ ជាជំនួស កសិករជាស្ត្រីមេម៉ាយគួរប្រើប្រាស់ទ្រុងតូចសម្រាប់ចិញ្ចឹមមាន់ធំបាន ប្រសិនបើលំបាកសងទ្រុងធំ។ ទំនាក់ទំនងល្អជាមួយកូន បងប្អូន និង អ្នកជិតខាង ជាកត្តាមួយដ៏សំខាន់ ដើម្បីចិញ្ចឹមមាន់ទទួលបានជោគជ័យ សម្រាប់ស្ត្រីមេម៉ាយ។ ប្រសិនបើមានទំនាក់ទំនងល្អ នោះស្ត្រីអាចពឹងពួកគេអោយជួយខ្លួន ដូចជាការសង់ទ្រុងធំជាដើម។ បន្ថែមជាងនេះទៀត ស្ត្រីមេម៉ាយអាចធ្វើការចែករំលែកដល់បងប្អូន និង អ្នកជិតខាង នូវចំណេះដឹង និងជំនាញរបស់ខ្លួនដែលរៀន ដែលនេះជាកត្តាមួយជួយបង្កើនទំនុកចិត្តរបស់ខ្លួន ក្នុងការចិញ្ចឹមមាន់ផងដែរ។

# បទពិសោធន៍នៃការអភិវឌ្ឍន៍ចិញ្ចឹមមាន់ជាជំហានៗ

(១)



ចិញ្ចឹមមាន់ (រួមទាំងមាន់ធំ) ក្នុងទ្រុងតូច

(២)



ចាប់ផ្តើមសង់ទ្រុងធំ សម្រាប់ចិញ្ចឹមមាន់

(៣)



ទ្រុងមាន់ធំ កំពុងសង់ សម្រាប់ចិញ្ចឹមមាន់

(៤)



ទ្រុងមាន់ធំសង់រួច តែមិនទាន់មានរបងព័ទ្ធជុំវិញ

(៥)



ចិញ្ចឹមមាន់ក្នុងទ្រុងធំ ដែលគ្មានរបងព័ទ្ធជុំវិញទីធ្លា

(៦)



ត្រូវចិញ្ចឹមកូនមាន់ក្នុងទ្រុងតូចជាប្រចាំ

(៧)



ទីធ្លាមានរបងព័ទ្ធជុំវិញ ត្រូវបានសង់រួចរាល់

(៨)



ដំណាំទ្រើងគ្របពីលើទីធ្លា សម្រាប់ជាម្លប់